# Royal University of Phnom Penh

## Master of Education Program

**ប្រសិទ្ធភាពនៃសាលាមត្តេយ្យទៅលើការសិក្សាដំបូងក្នុងថ្នាក់ទី១**

**The Effect of Pre-School on Early Learning in Graded One**

**Than Thavy**

December 2008

# Royal University of Phnom Penh

## Master of Education Program

**ប្រសិទ្ធភាពនៃសាលាមត្តេយ្យទៅលើការសិក្សាដំបូងក្នុងថ្នាក់ទី១**

**The Effect of Pre-School on Early Learning in graded one**

**Than Thavy**

A research report submitted in partial fulfilment of the requirements of the degree of Master of Education

**Supervisor: Dr. Chhinh Sitha**

Sponsored by: European Commission

© 2008 **Than Thavy**

December 2008

# មូលន័យសង្ខេប

"កុមារជាទំពាំងស្នងឫស្សី"ទំពាំងដុះពន្លកចេញមកល្អនោះឫស្សីក៏ប្រែក្លាយទៅជាមានប្រយោជន៏អាចប្រើប្រាស់បាន ។ ប្រសិនបើគេបានយកចិត្តថែបំប៉នលើកុមារទាំងផ្នែកចំណីអាហារនិងការអប់រំនៅសាលាមត្តេយ្យតាំងពីឆ្នាំដំបូង ដែលក្នុងនោះមត្តេយ្យសិក្សាចែកចេញជាបីកំរិតទៅតាមអាយុរបស់កុមារ ហើយមុខវិជ្ជាទាំងដប់នៅមត្តេយ្យសិក្សាដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍផ្នែកទាំងប្រាំរបស់កុមារអោយបានល្អនៅក្នុងកំឡុងវ័យដំបូងនៃមត្តេយ្យសិក្សា។ ដោយផ្អែកលើការសិក្សាស្រាវជាវដែលធ្វីឡើងក្នុងគោលបំណងចង់ស្វាបស្ទង់ លើកុមារដែលមានសាវតាឆ្លងកាត់មត្តេយ្យសិក្សា និងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យសិក្សាតើមានភាពខុសបែបណាខ្លះនិងកត្តាដែលបណ្តាលឱ្យពុំបានឆ្លងកាត់មត្តេយ្យសិក្សា។ តាមរយៈការស្រាវជ្រាវតាមបែបគុណតម្លៃដោយជ្រើសរើស កុមារ៣៦នាក់ ចំនួនពីរសាលា ក្នុងខេត្តកំពង់ធំ ។

ជាលទ្ធផលកុមារដែលមានសាវតាឆ្លងកាត់មត្តេយ្យសិក្សាគឺកុមារអាច សម្របសម្រួលខ្លួនទៅនឹងបរិស្ថានខាងក្រៅមានប្រាស័យទាក់ទងល្អក្នុងសង្គមកុមារមានភាពវ័យឆ្លាតមានទំនុកចិត្តខ្លួនឯង ខុសពីកុមារពុំមានសាវតាឆ្លងកាត់មត្តេយ្យ ។ ព្រមទាំងមានការចូលរួមមាតិរបស់អ្នកគ្រូលោកគ្រូដែលបានផ្តល់យោបល់ថា ការអប់រំនៅមត្តេយ្យសិក្សាជាគ្រឹះយ៉ាងមាំមួនក្នុងការជួយកុមារដែលរៀនថ្នាក់ទី១នៃបឋមសិក្សាអោយទទួលជោគជ័យ ។ កត្តាជោគជ័យនោះដែរមានការចូលរួមយ៉ាងសំខាន់ពីសំណាក់ឪពុក-ម្តាយអាណាព្យាបាលក្នុងការជួយរៀបចំជាផែនការច្បាស់លាស់មួយសំរាប់កូនៗតូចរបស់ពួកគេជាពិសេសផ្តល់លទ្ធភាពដល់កូនៗរបស់ពួកគាត់ដែលគ្រប់អាយុកាលត្រូវចូលរៀនថ្នាក់មត្តេយ្យ ។ ក្រៅពីការចូលរួមពីសំណាក់ឪពុក-ម្តាយអាណាព្យាបាលការចូលរួមពីសំណាក់សហគមន៏ និងសង្គមក៏មិនអាចមើលរំលងបានដែរ ។ ប៉ុន្តែអ្វីដែលគួរឱ្យសោកស្តាយ ចំពោះកុមារពុំបានទទួលការអប់រំនៅមត្តេយ្យក៏ដោយសារតែគ្មានសាលាសាលានៅឆ្ងាយពីលំនៅដ្ឋានជាការរំខានដល់ពេលវេលារបស់ឪពុកម្តាយ និងជីវភាពមានកម្រិតរួមទាំងការស្នើរសុំពីភូមិឃុំផ្តល់មត្តេយ្យសិក្សាពុំទាន់ទទួលការឆ្លើយតបនៅឡើយដែលជាកត្តាមួយអាក់ខានក្នុងការ ជួយសម្របសម្រួលសមត្ថភាពតាមវ័យរបស់កុមារ ពិសេសភាពជោគជ័យនៅបឋមសិក្សា។ និយាយជារួមការអប់រំកុមារតូចជាកិច្ចការរបស់យើងទាំងអស់គ្នាដែលត្រូវតែចូលរួមជាពិសេសរាជរដ្ឋា-ភិបាលក៏ដូចជាក្រសួងពាក់ព័ន្ធជួយក្នុងការចូលរួមពង្រឹងគុណភាពផ្នែកគាំពារ និងអភិវឌ្ឍកុមារតូចបន្ថែមទៀត ។

TO WHOM IT MAY CONCERN

Name of program: Master of Education Program

Name of candidate: **Than Thavy**

Title of research report:

**The Effect of Pre-School on Early Learning in graded one**

This is to certify that the research carried out for the above titled master's research report was completed by the above named candidate under my direct supervision. This material has not been used for any other degree. I played the following part in the preparation of the research report:

Supervisor: **Dr. Chhinh Sitha**

Date: 27  December 2008

# Royal University of Phnom Penh

TO WHOM IT MAY CONCERN

This is to certify that the research report that I, **Than Thavy,**

hereby present entitled **"The Effect of Pre-School on Early Learning in graded one. "** for the degree of Master of Education at the Royal University of Phnom Penh is entirely my own work and, furthermore, that it has not been used to fulfill the requirements of any other qualification in whole or in part, at this or any other university or equivalent institution.

No reference to, or quotation from, this document may be made without the written approval of the author.

Signed by Than Thavy

Date: 27 December 2008

Countersigned by the Chief Supervisor

………………………………………………………………………..

Date: 27 December 2008

# Royal University of Phnom Penh

**Masters of Education Program**

**Title of research report: The Effect of Pre-School on Early Learning in graded one.**

**Research report submitted by Than Thavy**

**Recommended textual statement..........................................................**

**..........................................................................................................**

**Research report committee members**

**Dr. Nith Bunlay**

Chairperson

**Dr. Chet Chealy**

External Examiner

**Dr. Keng Chansopheak**

Examiner

Date: 27 December 2008

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណលោកឪពុក អ្នកម្តាយជាទីគោរពស្រឡាញ់ ដែលបានចិញ្ចឹម បីបាច់ ថែរក្សា ឧបត្ថម្ភគាំទ្រលើកទឹកចិត្តនៅក្នុងការសិក្សាតាំងពីថ្នាក់មត្តេយ្យថ្នាក់ រហូតមកដល់ថ្នាក់ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់ការលះបង់ទាំងកម្លាំងកាយកម្លាំងចិត្តក្នុងការជួយជ្រោមជ្រែងជារៀងរហូតមក។

សូមថ្លែងអំណរផងដែរចំពោះស្វាមីជាទីស្រឡាញ់ដែលបានចំណាយពេលវេលា និងកម្លាំងក្នុងការរៀបសម្របសម្រួលនូវកិច្ចការនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកបណ្ឌិត ឈិញ ស៊ីថា ដែលលោកគ្រូបានជួយដឹកនាំបំភ្លឺផ្លូវជារៀងរហូតមក របាយការណ៍ស្រាវជ្រាវនេះមិនអាចបញ្ចប់បានទេបើមិនទទួលបានការណែនាំកែលំអពីសំណាក់លោកគ្រូ។ ជាថ្មីម្តងទៀតសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល និងសហគមន៍អឺរ៉ុបក្នុងកិច្ចប្រឹងប្រែងផ្តល់នូវអាហាររូបករណ៍ដល់មន្ត្រីរាជការដើម្បីពង្រីកចំណេះដឹងនិងបទពិសោធន៍ល្អៗដែល មានប្រយោជន៍ក្នុងការជួយបង្កើននូវធនធានមនុស្សសម្រាប់បំរើសង្គមជាតិ។

ជាចុងក្រោយបង្អស់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកគ្រូ-អ្នកគ្រូទាំងអស់ដែលបានខិតខំចំណាយកំលាំងកាយ និងប្រាជ្ញាក្នុងការផ្តល់ចំណេះដឹងដល់រូបនាងខ្ញុំក៏ដូចជាសិស្សទាំងឡាយដទៃទៀត។

# សារាងមាតិការ

**ចំណងជើង**........................................................................................................ **ទំព័រ**

បញ្ជីនៃតារាង ........................................................................................................ VIII

បញ្ជីនៃតួលេខ........................................................................................................ IX

សេចក្តីថ្លែងអំណរគុណ........................................................................................................ XI

១. ជំពូកទី១

១.១ សេចក្តីផ្តើម........................................................................................................ ១

១.២ គោលបំណង ........................................................................................................ ៦

១.៣ ការកំណត់បញ្ហា ........................................................................................................ ៦

១.៤ សំណួរនៃការសិក្សាស្រាវជ្រាវ ........................................................................................................ ៦

២.ជំពូកទី២ ការរំលឹកទ្រឹស្តី

២.១ សកម្មភាពជំរុញការអភិវឌ្ឍន៍កុមារ ........................................................................................................ ៧

២.២ តួនាទីសាលាមត្តេយ្យ ........................................................................................................ ១១

២.៣ ទស្សនះរបស់គរុវិទូលើកុមារ........................................................................................................ ១១

២.៤ ចិត្តវិទូកុមារ........................................................................................................ ១២

២.៥ ចំណេះដឹងមានស្រាប់របស់កុមារ........................................................................................................ ១៥

៣. ជំពូកទី៣

៣.១ ទំហំ និងវិធីសាស្រ្តនៃការស្រាវជ្រាវ ........................................................................................................ ១៩

៤. ជំពូកទី៤ របកគំហើញ

៤.១ របកគំហើញ........................................................................................................ ២១

៤.២ លទ្ធផល និងការពិភាក្សា........................................................................................................ ៣០

៤.៣ មូលហេតុដែលសិស្សមិនបានឆ្លងកាត់មត្តេយ្យ........................................................................................................ ៣២

ជំពូកទី៥ ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ ការសន្និដ្ឋាន........................................................................................................ ៣៤

៥.២ ការផ្តល់អនុសាសន៏........................................................................................................ ៣៥

ឯកសារយោង........................................................................................................ ៣៦

តារាងឧបសម្ពន្ធ័ ........................................................................................................ ៣៧

បញ្ជីនៃតារាង


៤.១.១ អភិវឌ្ឍផ្នែកសិសធមិ និងវប្បធមិ ............................................................ ២១

៤.១.២ អភិវឌ្ឍផ្នែកសុខភាព និងរាងកាយ ............................................................ ២៣

៤.១.៣ អភិវឌ្ឍផ្នែកភាសា............................................................ ២៥

៤.១.៤ អភិវឌ្ឍផ្នែកបញ្ញា និងការគិត............................................................ ២៧

៤.១.៥ អភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍............................................................ ២៩

បញ្ជីនៃតួលេខ


តារាងទី ៤.១.១

អថេរទី១ ........ ២២

អថេរទី២ ........ ២២

អថេរទី៣ ........ ២២

អថេរទី៤ ........ ២២

អថេរទី៥ ........ ២៣

តារាងទី ៤.១.២

អថេរទី១ ........ ២៤

អថេរទី២ ........ ២៤

អថេរទី៣ ........ ២៤

អថេរទី៤ ........ ២៤

អថេរទី៥ ........ ២៥

តារាងទី៤.១.៣

អថេរទី១ ........ ២៦

អថេរទី២ ........ ២៦

អថេរទី៣ ........ ២៦

អថេរទី៤ ........ ២៦

អថេរទី៥ ........ ២៧

អថេរទី៦ ........ ២៧

អថេរទី៧ ........ ២៧

អថេរទី៨ ........ ២៧

តារាងទី៤

អថេរទី១ ........ ២៨

អថេរទី២ ........ ២៨

អថេរទី៣ ........ ២៨

អថេរទី៤ ........ ២៨

អថេរទី៥ ........ ២៨

តារាងទី៥


អថេរទី១ .......................................................................................................... ២៩

អថេរទី២.......................................................................................................... ៣០

អថេរទី៣.......................................................................................................... ៣០

អថេរទី៤.......................................................................................................... ៣០

អថេរទី៥.......................................................................................................... ៣០

# ជំពូកទី១

## ១.១ សេចក្ដីផ្ដើម

បន្ទាប់ពីឆ្លងកាត់សង្គ្រាមជិតពីរទសវត្សកន្លងមក រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានពុះពារ ស្តារវិស័យអប់រំឡើងវិញ ក្នុងនោះមានការស្តារផ្នែកមត្តេយ្យសិក្សាដែលត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង។ ក្រសួងអប់រំយុវជននិងកីឡាបានបើកមត្តេយ្យសិក្សាឡើងវិញចាប់ពីឆ្នាំ១៩៨០។ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៨៦ ស្តីពីការអប់រំមត្តេយ្យសិក្សា និងដើម្បីពង្រឹងគុណភាពផ្នែកគាំពារ និងអភិវឌ្ឍកុមារតូចបន្ថែមទៀត ។

ប្រទេសនានានៅលើសកលលោក បានទទួលស្គាល់តំរូវការដ៏សំខាន់នៃអន្តរាគមន៍សម្រាប់ការអភិវឌ្ឍកុមារតូចដើម្បីសំរេចគោលដៅអប់រំសម្រាប់ទាំងអប់រំគ្នា ។ ប្រទេសទាំងនោះបានផ្តល់យោបល់និងបង្ហាញការប្តេជ្ញាចិត្តលើការអភិវឌ្ឍកុមារតូចក្នុងសន្និសិទ្ធពិភពលោកស្តីពី ការអប់រំសម្រាប់ទាំងអស់គ្នានៅជុំទៀនប្រទេសថៃនាឆ្នាំ១៩៩០។ ការចាប់អារម្មណ៍លើការងារការអប់រំកុមារតូចនេះផ្តើមចេញពីកង្វល់នៃលទ្ធផលសិក្សារបស់កុមារនៅសាលាបឋមសិក្សាដែលអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សាមានកំរិតខ្ពស់ជារៀងរាល់ឆ្នាំ។

ការសិក្សា និងការស្រាវជ្រាវរបស់បណ្តាប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍបានបង្ហាញកត្តាជាច្រើនដែលទាក់ទងដល់អត្រាត្រួតថ្នាក់និងបោះបង់ការសិក្សានៅសាលាបឋមសិក្សាដូចជាបញ្ហាសុខភាពកង្វះការថៃទាំការអប់រំកុមារអាយុក្រោម៦ឆ្នាំ ដែលជាវ័យកំពុងលូតលាស់ទាំងរូបរាងកាយបញ្ញានិងសង្គម ។ ប្រការនេះទាមទារឆ្លងកាត់ការរៀនសូត្រទាំងនៅក្នុងសាលានិងក្នុងជីវភាពរស់នៅរបស់គេឱ្យបានទាន់ពេលវេលាព្រោះនៅពេលដែលកុមារបានទទួលការអប់រំពីផ្ទះទារកដ្ឋាន មត្តេយ្យសិក្សាមណ្ឌលថៃទាំកុមារ ពោលគឺបាលទទួលការអភិវឌ្ឍល្អកុមារទាំងនោះអាចនឹងមានសក្តានុភាពក្នុងការសិក្សានៅបឋមសិក្សាដោយពុំមានត្រួតថ្នាក់បោះបង់ការសិក្សា និងមានលទ្ធភាពបន្តការសិក្សាទៅថ្នាក់លើទៀត។

បច្ចុប្បន្ននេះនៅប្រទេសកម្ពុជាមានសាលាមត្តេយ្យសិក្សាច្រើនប្រភេទ ក៏ប៉ុន្តែសាលាមត្តេយ្យសិក្សាទាំងនោះពុំទាន់អាចបំពេញតំរូវការរបស់កុមារបាននៅឡើយ ទាំងបរិមាណ និងគុណភាពជាពិសេសចំពោះកុមារនៅក្នុងតំបន់ជនបទ និងដាច់ស្រយាល។

ឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តការអប់រំទាំងអស់គ្នា និងគោលការអប់រំជាតិក្រសួងអប់រំយុវជននិង កីឡាបានសហការជាមួយក្រសួងពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីកែលំអគុណភាពការអភិវឌ្ឍកុមារតូច ក្នុងនោះបានកែលំអប្រព័ន្ធអប់រំនៅមត្តេយ្យសិក្សា ដោយបើកទូលាយបន្ថែមទៀតសាលាមត្តេយ្យសិក្សាឯកជន សាលាមត្តេយ្យសហគមន៍ កែលំអកម្មវិធីសិក្សា និងសៀវភៅសិក្សាបំរើ

ឱ្យមត្តេយ្យសិក្សាបច្ចុប្បន្ន ។ អនាគតដ៏ខ្លី ខាងមុខនេះ ក្រសួងអប់រំ យុវជន និងកីឡា និងខិតខំប្រឹងប្រែង ពង្រីកសេវាអប់រំកុមារតូចបន្ថែមទៀត រួមទាំងការអប់រំតាមខ្នងផ្ទះ និងការអប់រំមាតាបិតា អ្នកថែទាំកុមារ ឱ្យយល់ដឹងអំពីសកម្មភាពអភិវឌ្ឍកុមារតូចដើម្បីឱ្យកុមារទាំងអស់រួមទាំងកុមារក្រីក្រលំបាក កុមារពិការ និងកុមារជនជាតិភាគតិចបានទទួលការអប់រំល្អ ។

ឆ្នាំសិក្សា២០០៦-០៧ នេះ សាលាមត្តេយ្យទូទាំងប្រទេសសរុបមានចំនួន ២.៦៤១ កន្លែង កើនឡើងចំនួន ១៧៤កន្លែង ក្នុងនោះយើងមានសាលាមត្តេយ្យដាច់ដោយឡែក ១២៩សាលា និងសាលាពាក់កណ្ដាល អន្តរវាំសិកដ្ឋាន ចំនួន១(ខេត្តកណ្ដាល) ។ ថ្នាក់សរុបចំនួន ៤.០៦១ថ្នាក់ កើនឡើងចំនួន ៣៤១ថ្នាក់ កុមារទូទាំងប្រទេសសរុបចំនួន ១៣០.២៨៨នាក់ ស្រី ៦៥.៧៦៨នាក់ កើនឡើងចំនួន ១០.១៩នាក់ ស្មើនឹង ៧.៨២% បុគ្គលិកសរុបចំនួន ៤.៩២៣នាក់ ស្រី ៤.៦៨០នាក់ កើនឡើងចំនួន ៩៥នាក់ ស្មើនឹង ១.៩៣% ក្នុងនោះយើងមាន :

មត្តេយ្យសិក្សារដ្ឋមាន១.៥២៤កន្លែង(សាលាមត្តេយ្យសិក្សាដាច់ដោយឡែកពីបឋមសិក្សាចំនួន១២៩ កន្លែង) ថ្នាក់សរុបចំនួន ២៥៤៨ថ្នាក់ កុមារសរុបចំនួន ៧៧.៨៩៩នាក់កើន ឡើងចំនួន ២.២៣០នាក់ស្មើនឹង ២.៨៦% បុគ្គលិកសរុបចំនួន ២.៩៧៨នាក់ ស្រី ២.៩១៧ នាក់ ។

មត្តេយ្យសិក្សាឯកជនមាន ១០០កន្លែង ថ្នាក់សរុបចំនួន ៣៦១ថ្នាក់ កុមារសរុបចំនួន ៩.៥៦៥នាក់ ស្រី ៤.១៨៣នាក់ កើនឡើង ១.០៥៣នាក់ ស្មើនឹង ១១% បុគ្គលិកមានចំនួន ៧៣៦នាក់ ស្រី ៥៦៨នាក់ ។

មត្តេយ្យសិក្សាសហគមន៍មាន ១.០១៧កន្លែង ថ្នាក់សរុបចំនួន ១.១៥២ថ្នាក់ កុមារសរុប ចំនួន ២៣.៤៥៦នាក់ ស្រី ១២.៣៣៦នាក់ កើនឡើងចំនួន ១.១៩១នាក់ ស្មើនឹង ៥% បុគ្គលិកសរុបចំនួន ១.២០៩នាក់ ស្រី ១.១៩៥នាក់ ។

អប់រំកុមារតូចតាមផ្ទះមានកុមារសរុបចំនួន ១៩.៣៦៨នាក់ ស្រី ៩.៦៦៣នាក់ កើនឡើង ចំនួន ៥.៩២១នាក់ ស្មើនឹង ៣០% ។

កុមារអាយុ៣-៥ឆ្នាំក្នុងឆ្នាំសិក្សា២០០៦-០៧ បានទទួលការអប់រំតាមគ្រប់កម្មវិធីអប់រំកុមារតូចសរុបចំនួន ១៨៩ .៨៧៤ នាក់ ស្រីចំនួន៦៥.៤៥៤នាក់ កើនឡើងចំនួន ៦៩.៧៧៦នាក់ ស្មើនឹង ៣៦.៧៤% គិតជាភាគរយនៃចំនួន ប្រជាពលរដ្ឋជាកុមារ ស្មើនឹង ១៥% និង កុមារអាយុ៥ឆ្នាំ សរុបចំនួន ៨២.៤៦៧នាក់ ស្រីចំនួន ៤១.២៣៨នាក់ កើនឡើង ចំនួន ៣.០១៣ នាក់ ស្មើនឹង ៣.៦៥% គិតជាភាគរយនៃចំនួនប្រជាពលរដ្ឋជាកុមារស្មើនឹង ២៩.៨៣% ។ នៅចុងឆ្នាំ សិក្សា២០០៦-០៧នេះ កុមារអាយុ៥ឆ្នាំ ដែលបានឆ្លងកាត់ថ្នាក់កម្រិតខ្ពស់ត្រូវបានចូលរៀននៅថ្នាក់ទី១ នៅសាលាបឋមសិក្សាមាន ៨០.៩៩៨នាក់ ស្រី ៤០.៦៦៧នាក់ កើន៣,០១៣នាក់ ស្មើនឹង៣,៦៥ % ។(សូមមើលតារាងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ។)

ការសម្រេចលទ្ធផលប្រកបដោយផ្លែផ្កាទាំងនេះបាន ក៏អាស្រ័យដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងអប់រំយុវជន និងកីឡាគ្រប់លំដាប់ថ្នាក់សហការល្អជាមួយអង្គការជាតិ អន្តរជាតិ និងសប្បុរសជននានា ព្រមទាំងស្ថាប័នពាក់ព័ន្ធ ផ្សេងៗជាពិសេស សហគមន៍ផងដែរ។

១.១គោលនយោបាយនៃការគាំពារ និងអភិវឌ្ឍកុមារតូច

-យោងព្រះរាជក្រិត្យលេខ ២១ អនក្រ ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា

-យោងអនុក្រិត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០២ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធនៃនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច

-យោងសេចក្ដីប្រកាស និងសន្និសទិ្ធ ពិភពលោកស្ដីពីការអប់រំ សម្រាប់ទាំងអស់គ្នាឆ្នាំ១៩៩០ នៅជុំទៀន ប្រទេស ថៃ និងឆ្នាំ២០០០ នៅដាករកា ប្រទេសនៃប្រទេស សេណេហ្កាល។

-អនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

-គោលដៅអប់រំជាតិ

-ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥

-អនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

ស្ដីពីការអភិវឌ្ឍន៍ធនធានមនុស្សដោយកំណត់ថា (មាគ៌ាចម្បង នៃការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយសុខភាពមាំមួន មានចំណេះវិជ្ជា និងវប្បធម៌ខ្ពង់ខ្ពស់)។ ការគាំពារ និងអភិវឌ្ឍកុមារតូចគឺជាគ្រឹះនៃការអប់រំមូលដ្ឋាន។ ដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា វាជាការចាំបាច់ណាស់ឱ្យមានការប្ដេជ្ញាចិត្តលើការងារគាំពារ និងអភិវឌ្ឍកុមារតូច និងជួយគាំទ្រដល់គ្រួសារ និងសហគមន៏ដែលជាអ្នកដើរតួមួយយ៉ាងសំខាន់ក្នុងការងារអប់រំកុមារតូច។

ក្រសួងអប់រំយុវជន និងកីឡាបានបង្កើតគោលនយោបាយ ស្ដីពីការងារ អប់រំកុមារតូចសម្រាប់កុមារពីអាយុ៣ទៅ ក្រោម ៦ឆ្នាំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមការចុះហត្ថលេខា ដោយឯកឧត្តម តុល ឡោះរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡានាថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០០។ គោលនយោបាយនោះបានចែងថា ក្រសួងអប់រំយុវជននិងកីឡាមានគោលនយោបាយស្ដីពីការអប់រំកុមារតូចដូចខាងក្រោម

១.ការអប់រំកុមារតូចត្រូវចាត់ទុកជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធអប់រំ។

២. ការអប់រំកុមារតូចត្រូវបញ្ចូលការអភិវឌ្ឍកុមារឱ្យបានពេញលេញគ្រប់ផ្នែកទាំងអស់ (ការអភិវឌ្ឍបុគ្គលិក លក្ខណះ ចិត្ត ចលនា និងបញ្ញា)។

៣.ក្រសួងអប់រំយុវជន និងកីឡា យកចិត្តទុកដាក់ និងទទួលខុសត្រូវលើការអប់រំកុមារតូច ក្នុងវ័យមត្តេយ្យសិក្សា ដែលមានអាយុពី៣ ទៅក្រោម៦ឆ្នាំ។

៤.ការអប់រំកុមារតូច ត្រូវធ្វើឱ្យបានដល់កុមារទាំងអស់ រួមទាំងកុមារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការ លំបាក។

៥. ប្រព័ន្ធផ្តល់សេវាសម្រាប់ការអប់រំកុមារតូច ត្រូវធ្វើឡើងតាមរូបភាពចម្រុះ ឱ្យបានច្រើន ដែលអាចជ្រើសរើស បានតាមស្ថានភាពជាក់ស្តែងរបស់កុមារ( ស្ថាប័នរដ្ឋ ឯកជន ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ ) និងត្រូវមានការចូលរួមពីសហគមន៍ ដើម្បីធានាផ្តល់ការអប់រំ ឱ្យបានដល់កុមារទាំងអស់។

៦. គោលការណ៍ណែនាំថ្នាក់ជាតិ កម្មវិធីសិក្សា ឯកសារស្រាវជ្រាវផ្សេងៗ ត្រូវផ្តល់ ឱ្យបានគ្រប់គ្រាន់ ដើម្បី សម្រួល ដល់ការអប់រំកុមារតូចឱ្យបានពេញលេញ។

៧. មន្ត្រីគ្រប់គ្រង បុគ្គលិកសិក្សា រួមទាំងឪពុក-ម្តាយ អ្នកថែទាំកុមារដែល ជាអ្នកផ្តល់ ការអប់រំដល់កុមារតូច នៅតាមប្រព័ន្ធផ្តល់សេវាចម្រុះត្រូវតែមានសមត្ថភាពពេញលេញទៅតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

៨.នៅតាមប្រព័ន្ធផ្តល់សេវាអប់រំកុមារតូច ក្នុងស្ថាបន័រដ្ឋ-ឯកជន ក្នុងប្រព័ន្ធ-ក្រៅប្រព័ន្ធ ត្រូវមានសម្ភារៈបរិក្ខារ ឱ្យបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់កុមារតូច។

៩.ការតាមដានត្រួតពិនិត្យគុណភាពអប់រំកុមារតូច ត្រូវធ្វើឡើងតាមរយៈរចនាសម្ព័ន្ធរបស់ ក្រសួងអប់រំយុវជន និងកីឡា ដោយសហការជាមួយក្រសួង អង្គការពាក់ព័ន្ធ និងសហគមន៍។

១០.ក្រសួងអប់រំយុវជននិងកីឡារៀបចំបង្កើតគណៈកម្មការសម្របសម្រួល ការងារអប់រំកុមារ តូចថ្នាក់ក្រសួង ដែលមានតំណាងមកពីនាយកដ្ឋានពាក់ព័ន្ធ និងសហការជាមួយគណៈកម្មការសម្រប សម្រួល សម្រាប់ការគាំពារ និងអភិវឌ្ឍកុមារតូចថ្នាក់ជាតិ។

ប្រព័ន្ធផ្តល់សេវាចម្រុះរួមមានៈ

+ សាលាមត្តេយ្យសិក្សាក្នុងប្រព័ន្ធ

-សាលាមត្តេយ្យសិក្សារដ្ឋ

-សាលា/ថ្នាក់មត្តេយ្យសិក្សា នៅក្នុងបរិវេណសាលាបឋមសិក្សា

-សាលាមត្តេយ្យសិក្សារោងចក្រ សហគ្រាស

-សាលាមត្តេយ្យសិក្សាឯកជន

+ សាលា/ថ្នាក់មត្តេយ្យសិក្សាក្រៅប្រព័ន្ធ

-សាលាមត្តេយ្យសិក្សាសហគមន៍

-មត្តេយ្យសិក្សាតាមខ្នងផ្ទះ

+ ការអប់រំក្រៅប្រព័ន្ធ នៅតាមផ្ទះដើម្បីមត្តេយ្យសិក្សា( ការអប់រំកុមារតូច នៅតាមផ្ទះ)

សេវាកម្មអប់រំក្រៅប្រព័ន្ធ ត្រូវមានការគាំទ្រពីសហគមន៍ និងគ្រួសារ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចាត់ទុកថាការគាំពារ និងអភិវឌ្ឍកុមារតូចជាប្រព័ន្ធអប់រំមួយរួម ចំណែកសម្រេចនូវការងារអប់រំសម្រាប់ទាំងអស់គ្នា និងបង្កលទ្ធភាពឱ្យប្រជាជន មានឱកាសទទួលការអប់រំពេញមួយជីវិត ដើម្បីកសាងសង្គមប្រកបដោយសមធម៌ យុត្តិធម៌ និងអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលបានទទួលស្គាល់សារៈប្រយោជន៍នៃការគាំពារ និងអភិវឌ្ឍន៍កុមារតូចប្រកបដោយគុណភាពដើម្បីជា ឧត្តមប្រយោជន៍ដល់អនាគតរបស់កុមារម្នាក់ៗ ដែលជាសសរទ្រូង និងជាអនាគតនៃប្រទេសជាតិ ។ ការគាំពារនិងអភិវឌ្ឍកុមារតូចជាចំណែកមួយដែលមិនអាចខ្វះបាននៃការអប់រំសម្រាប់ទាំងអស់គ្នានិងជាគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលដូច្នេះហើយបានជារាជរដ្ឋាភិបាលចាត់ទុកការគាំពារ និងអភិវឌ្ឍន៍កុមារតូចមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍធនធានមនុស្ស ។ជាពិសេសរាជរដ្ឋាភិបាលទទួលស្គាល់សារៈសំខាន់នៃការយកចិត្តទុកដាក់លើក្រុមកុមារវ័យដំបូងទាំងអស់ ពី0ទៅក្រោម៦ឆ្នាំ និងការយកចិត្តទុកដាក់លើផ្នែកសុខភាព និងអាហារ រូបបថមលើកុមារទាំងនោះ ។

ដោយបន្ថែមលើគោលនយោបាយរបស់ក្រសួងអប់រំយុវជន និងកីឡា ( ឆ្នាំ២000)ដែល ផ្តោតលើការអប់រំកុមារ តូច និងមានក្រុមគោលដៅ ៣ទៅក្រោម៦ឆ្នាំគោលនយោបាយថ្មី:

១.ការគាំពារនិងអភិវឌ្ឍន៍កុមារតូចពី0ទៅក្រោម៦ឆ្នាំ ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះក្នុងការលើកំពស់ ការរស់រាន់មានជីវិតរបស់កុមារដោយពុំមានការប្រកាន់ជាតិសាសន៍ ពូជសាសន៍ សាសនា និងភេទអ្វីឡើយជាពិសេសកុមារដែលជួបការលំបាក និងកុមារងាយរងគ្រោះ ក្នុងនោះរួមមានកុមារពិការត្រូវបានទទួលនូវការយកចិត្តទុកដាក់ធានាឱ្យបានចូលក្នុងកម្មវិធីសេវានៃការគាំពារ និងអភិវឌ្ឍកុមារតូច ។

២.ប្រព័ន្ធផ្តល់សេវាសម្រាប់ការគាំពារ និងអភិវឌ្ឍន៍ ត្រូវធ្វើឡើងតាមរូបភាពចម្រុះដោយផ្អែកតាមស្ថានភាពជាក់ ស្តែងរបស់កុមារ (ស្ថាប័នរដ្ឋ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ សហគមន៍ ឯកជន និងតាមខ្នងផ្ទះ) ព្រមទាំងត្រូវមានការចូលរួមគាំទ្រ ពីសហគមន៍ជាតិ និងអន្តរជាតិ ។

៣.ការគាំពារ និងអភិវឌ្ឍន៍កុមារតូចត្រូវអភិវឌ្ឍកុមារឱ្យបានពេញលេញលើគ្រប់ផ្នែក ទាំងអស់( សុខភាព អាហាររូបត្ថម្ភ ការអភិវឌ្ឍបុគ្គលិកលក្ខណៈ សោភ័ណ អប់រំផ្លូវចិត្តបញ្ញា និងចិត្តចលករ) ។

៤. គ្រប់ក្រសួងពាក់ព័ន្ធ ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងសហការជាមួយក្រសួងអប់រំយុវជន និងកីឡាដើម្បីឱ្យក្រសួងអប់រំយុវជន និងកីឡាអាចរៀបចំបង្កើតយន្តការសម្រាប់ការងារគាំពារ និង

អភិវឌ្ឍន៍កុមារតូចនិងជាពិសេសជួយគាំទ្រលើការងារបញ្ចុះបញ្ចូលការធ្វើកម្មវិធីសិក្សាការរៀបចំបទដ្ឋាន ឯកសារ អធិការកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈថវិការ និងការ អភិវឌ្ឍន៍ធនធានមនុស្ស។

### ១.២ គោលបំណង

គោលបំណងនៃការសិក្សាស្រាវជ្រាវ នេះគឺ:

- ស្វែងយល់ពីភាពខុសគ្នារវាងកុមារដែលបានឆ្លងកាត់មត្តេយ្យ ធៀបជាមួយកុមារដែលមិនបានឆ្លងកាត់មត្តេយ្យ

-ស្វែងយល់ពីការអភិវឌ្ឍន៍ផ្នែកទាំង៥របស់កុមារ ដែលបានឆ្លងកាត់មត្តេយ្យ (១.អភិវឌ្ឍរូបរាងកាយ និងសុខភាព ២.សីលធម៌ និងវប្បធម៌ ៣.សង្គម និងអារម្មណ៍ ៤.ការយល់ដឹង និងការពិចារណា ៥.ផ្នែកភាសា) ទៅតាមលក្ខណៈស្តង់ដារ ។

### ១.៣ ការកំណត់បញ្ហា

ការអប់រំកុមារតូចត្រូវបានមើលឃើញដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ថាជាកម្មវិធីអាទិភាពមួយ ក្នុង ចំណោមកម្មវិធីអាទិភាពជាច្រើននៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខ្លួន ។ ការអប់រំកុមារតូចត្រូវបាន គេទទួលស្គាល់ ថាជាយុទ្ធសាស្ត្រសំខាន់មួយក្នុងការជំរុញឱ្យមានអត្រាចុះឈ្មោះចូលរៀនកាត់បន្ថយការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាយឺតយ៉ាវនិងជួយកសាងមូលដ្ឋាន គ្រឹះសំរាប់កុមារដើម្បីចូលរៀនថ្នាក់ទី១ នៅ បឋមសិក្សា។

### ១.៤ សំណួរនៃការសិក្សាស្រាវជ្រាវ

តើកុមារដែលបានឆ្លងកាត់មត្តេយ្យនិង កុមារដែលមិនបានឆ្លងកាត់មត្តេយ្យមានការអភិវឌ្ឍខុសគ្នាដែរទេ?

# ជំពូកទី២ ការរំលឹកទ្រឹស្តី

## ២.១ សម្ថភាពជំរុញការអភិវឌ្ឍរបស់កុមារ

គឺឋិតនៅក្នុងដំនាក់កាសអាយុ ៦ ឆ្នាំដំបូងនៃជីវិតនេះហើយ ដែលកុមារបានកសាងឡើងនូវមូលដ្ឋានគ្រឹះនៃ បុគ្គលិកលក្ខណៈរបស់ខ្លួន ។ ហើយក៏ឋិតនៅក្នុងដំនាក់កាលជាមួយគ្នានេះដែរ ដែលបណ្តាមូលដ្ឋានគ្រឹះនេះកំនត់តិរិយាបថ របស់កុមារពេលក្លាយទៅជាមនុស្សពេញវ័យ ។

បើសិនជាអភិវឌ្ឍរបស់កុមារ មានដំណើរប្រព្រឹត្តទៅដោយប្រក្រតីល្អនៅក្នុងដំនាក់កាលនេះ កុមារពិតជានឹងទទួល បាននូវលំនឹងមួយ ហើយដែលលំនឹងនេះនឹងផ្តល់ជាគុណប្រយោជន៏ អោយកុមារវិញបានពេញមួយជីវិត ។ដូចនេះគេចាំ បាច់ត្រូវយកចិត្តទុកដាក់ចំពោះដំនាក់កាលនេះ អោយបានជិតដល់បំផុត ។ រាល់កង្វះខាតផ្សេងៗ ដែលអាចកើតបាននៅ ដំនាក់កាលនេះអាចនឹងនាំអោយមានផលវិបាកដ៏ធ្ងន់ធ្ងរ និងបង្កអោយមានការប៉ះពាល់ខូចខាតដល់ការសិក្សារបស់កុមារនាពេលអនាគតមិនអាចជៀសរួចបានឡើយ ។

វ័យមត្តេយ្យសិក្សា គឺ ជាវ័យមួយដែលកុមារតូចឈានទៅទទួលបានបន្តិចម្តងៗ នូវសមត្ថភាពក្នុងការធ្វើការសំរបសំរួលក្នុងការធ្វើការសហការជាមួយកុមារដទៃ ។ឋិតនៅក្នុងវ័យនេះដែរ រាងកាយរបស់កុមារមានសភាពកាន់តែទន់ភ្លន់ឡើងៗ ហើយចលនាដៃរបស់កុមារក៏មានសភាពកាន់តែប៉ិនប្រសប់ជាងពីមុនផងដែរ ។ វ័យមត្តេយ្យសិក្សាគឺជាវ័យមួយដែលកុមារចាប់ផ្តើមយល់បន្តិចម្តងៗពីភាសាពាក្យសំដីរបស់អ្នកដែលនៅជុំវិញខ្លួន ដែលកុមារក្លាយទៅជាមនុស្សមានសមត្ថភាពអាចនិយាយពីអ្វីដែលខ្លួនបានសង្កេតឃើញ និងមានក្នុងនៅចិត្តអាចនិយាយបញ្ជាក់បានពីទំនាក់ទំនងរវាងហេតុហើយនឹងផលរវាងលំហហើយនឹងពេលវេលាដែលខ្លួនកំពុងស្វែងយល់ ហើយអាចរំលឹកពីអនុស្សាវរីយ៏ការចងចាំរបស់ខ្លួនឡើងវិញបានទាំងអស់ ។ គឺដោយសារការធ្វើសមត្ថភាពជាមួយវត្ថុផ្សេងៗនិងដោយសារការព្យាយាមធ្វើត្រាប់តាមបងៗរបស់ខ្លួននេះហើយដែលកុមារតូចធ្វើការហ្វឹកហាត់និងអភិវឌ្ឍសមត្ថភាពផ្សេងៗរបស់ខ្លួនព្រមៗគ្នាដែរ ។

ដើម្បីអភិវឌ្ឍអោយល្អ កុមារត្រូវការធ្វើចលនា ( កំរើ ) សំដែងចេញនូវអ្វីៗ ដោយឯកឯងគ្មានបង្ខិតបង្ខំ ។ នៅពេលបានធ្វើចលនាផ្សេងៗតាមចំនង់ និងសេចក្តីត្រូវការរបស់ខ្លួនហើយកុមារនឹងទទួលបាននូវភាពងាយស្រួលក្នុងការធ្វើ ចលនារបស់រាងកាយបន្តិចម្តងៗ កុមារនឹងធ្វើអោយកាយវិកាយផ្សេងៗរបស់ខ្លួន មានភាពកាន់តែជាក់លាក់ឡើងៗ កុមារ នឹងឈានទៅត្រួតត្រាលើផ្នែកចលករបានយ៉ាងល្អប្រសើរ ហើយដែលទាំងអស់នេះមានសភាពចាំបាច់បំផុតចំពោះការហាត់រៀនរបស់កុមារនៅឯសាលាក្នុងពេលអនាគត ។

កុមារត្រូវការធ្វើទំនាក់ទំនងជាមួយអ្នកដទៃហើយចង់អោយអ្នកដទៃស្តាប់ខ្លួនជានិច្ច កុមារត្រូវការស្រាវជ្រាវ កុមារត្រូវស្វែងយល់និងរកឃើញពីពិភពមនុស្សដោយខ្លួនឯង ។

ដើម្បីឆ្លើយតបទៅនឹងការលូតលាស់ឥតឈប់ឈររបស់កុមារនេះមនុស្សចាស់ត្រូវតែយកចិត្តទុកដាក់ធ្វើយ៉ាងណាដើម្បីណែនាំកុមារអោយចេះពង្រឹងរាល់ចំនេះដឹងដែលខ្លួនទទួលបានរួចមកហើយ ឱ្យកុមារចេះបំបែកនិងធ្វើអោយចំនេះដឹងទាំងនេះកាន់តែទូលំទូលាយឡើងថែមទៀតតាមរយៈការផ្តល់ ឱ្យកុមារនូវឱកាសដ៏សមស្របដើម្បីអនុវត្តជាក់ស្តែងរាល់ បំនិនដែលខ្លួនមាននោះ ។

ប៉ុន្តែដើម្បីរីកចំរើនឡើងបានកុមារក៏ត្រូវការដឹងច្បាស់នៅក្នុងខ្លួនថាខ្លួនត្រូវបានគេស្រលាញ់និងស្វាគមន៍ចំពោះវត្តមានរបស់ជានិច្ច ។ កុមារត្រូវការសន្តិសុខ រីសុវត្ថិភាពនេះគឺកើតចេញមកពីភាពស្រលាញ់ ភាពកក់ក្តៅនិងការគាំទ្រដែលអ្នកនៅជុំវិញកុមារផ្តល់ឱ្យទៅកុមារ ។ យ៉ាងណាមិញតាមរយៈការសិក្សាស្រាវជ្រាវមួយចំនួនដែលគេបានធ្វើឡើងស្តីពីអាកប្បកិរិយារបស់កុមារបានបង្ហាញអោយឃើញថា ជាទូទៅចំពោះកុមារម្នាក់ដែលទទួលបាននូវសន្តិសុខពីអ្នកដែលនៅជុំវិញខ្លួនតែងមានចរិតសកម្មជាងមានការភ័យខ្លាចតិចជាង មានទំនុកចិត្តច្រើនជាងនិងបង្ហាញអោយឃើញថាចេះមានការចាប់អារម្មណ៍និង ចង់ចេះដឹងចង់ឃើញច្រើនជាងកុមារម្នាក់ទៀតដែលគ្មានសន្តិសុខផ្ទាល់ខ្លួនទៅទៀត ។

ជាមួយគ្នានេះ គេពុំគប្បីធ្វេសប្រហែសចំពោះការផ្តល់ និង ការបំប៉នចំនីអាហារអោយបានជិតដល់កុមារឡើយ ។ ដើម្បីអភិវឌ្ឍបានល្អ កុមារត្រូវការចំនីអាហារមួយដ៏ល្អ ។ ដូចគ្នានឹងយានយន្តមួយដែល ត្រូវការប្រេងឥន្ធនៈដើម្បីបើកបរទៅមុខបាន ដូច្នោះដែរកុមារត្រូវការថាមពលដែលផ្តល់អោយដោយចំនីអាហារដែលកុមារញុំាចូលទៅរាល់ថ្ងៃ ។ ឧ. គ្រាប់ធញ្ញជាតិផ្សេងៗ ស្រូវ ពោត បន្លែ ប៊ឺរ ប្រេងធញ្ញជាតិ សុទ្ធសឹងជាអាហារដែលផ្តល់អោយកុមារនូវថាមពលចាំបាច់ ក្នុងការធ្វើអោយប្រព័ន្ធ ចលករទាំងអស់នៅក្នុងខ្លួន មានដំណើរប្រព្រឹត្តទៅជាប្រក្រតី ។ អាហារផ្សេងៗទៀតដូចជាស្លឹកឈើ ផ្លែឈើនិងបន្លែផ្សេងៗអាច ជួយការពារកុមារទប់ទល់នឹងជំងឺមួយចំនួនបាន ។ សាច់ ត្រី ទឹកដោះគោ សណ្តែកដី សុទ្ធសឹងជាអាហារដែលសម្បូរទៅដោយជាតិប្រូតេអ៊ីន អាចជួយដល់ការកសាងរាងកាយរបស់កុមារនិងអាចជួយអោយកុមាររីកចំរើនធំធាត់ ឡើងយ៉ាងល្អ ។

កុមារត្រូវការពេលវេលាខ្លះដើម្បីគេង និង សំរាកផងដែរ ។ យ៉ាងណាមិញ រាល់ចំនេះដឹងរបស់កុមារត្រូវបានពង្រឹង ជាពិសេសនៅពេលដែលកុមារគេងលក់នោះ ។ ពេលខ្លះ កុមារអាចបង្ហាញអោយយើងឃើញច្បាស់ថាមានការហត់នឿយខ្លាំងណាស់ ។ ដូច្នេះ គេត្រូវតែយកចិត្តទុកដាក់ស្តាប់កុមារ និងផ្តល់អោយកុមារនូវឱកាសបានសំរាកខ្លះ ។

នៅទីបំផុតសុខភាពនៅតែជាមូលដ្ឋានមួយក្នុងចំនោមមូលដ្ឋានដទៃទៀត ដែលកំនត់ការលូតលាស់និង ការអភិវឌ្ឍរបស់កុមារ ។ កុមារម្នាក់ដែលមានសុខភាពល្អមុនជានឹងមានរាងកាយសកម្មស្វាហាប់ រហ័សរហួន ហើយមានការចង់ដឹងចង់ឃើញ មិនចេះឈប់ឈរ និងមានបញ្ហាទៀតផង ។

ដើម្បីបង្ការបញ្ហាផ្សេងៗដែលអាចកើតឡើងចំពោះសុខភាពកុមារ គេចាំបាច់ត្រូវតែគោរព ក្បួនអនាម័យអោយបានខ្ជាប់ខ្ជួនត្រូវតាមដានការលូតលាស់របស់កុមារអោយបានទៀតទាត់ ត្រូវបញ្ចៀសគ្រប់គ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងចំពោះកុមារត្រូវចាក់ថ្នាំបង្ការអោយកុមារនិង ត្រូវធ្វើអន្តរាគមន៍អោយបានទាន់ពេលវេលាកាលបើមានបញ្ហាអ្វីមួយកើតឡើងចំពោះកុមារ ។

ឆ្លងតាមសកម្មភាពនៃការស្រាវជ្រាវការរុករក និងលទ្ធភាព ដុះដាលរីកចំរើនរបស់វិញ្ញាណ របស់កុមារ និងកោសិការរបស់ខួរក្បាលមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត ។ការប្រទាក់គ្នានេះ រីកចំរើនទៅតាមកំរិតរបស់ខួរក្បាលជាលំដាប់រវាងកោសិការខួរក្បាលនិង ប្រព័ន្ធសរសៃប្រសាទអភិវឌ្ឍ ធ្វើឱ្យចំណុះរបស់ខួរក្បាលកើនឡើង ការអភិវឌ្ឍរបស់ខួរក្បាលមានកំរិតអាស្រ័យនិង ពេលវេលាកុមារអាយុ ៦ឆ្នាំ ខួរក្បាលរបស់គេអភិវឌ្ឍ ស្ទើតែពេញលេញទៅហើយ ។ ចំណុចដែលគួឱ្យចាប់អារម្មណ៍លើការអភិវឌ្ឍមានដូចជា :

- រាងកាយ

ពេលដែលកុមារមានភាពរហ័សរហួនពេលនោះកុមារនឹងទទួលបាននូវភាពម្ចាស់ការយ៉ាង ប្រសើរលើរាងកាយនិង វិញ្ញាណទាំង៥របស់ខ្លួនកុមារនឹងកាន់តែមានសមត្ថភាពចាប់និង ទទួលពត៌មានពីខាងក្រៅហើយ ផ្តើមចេញពីនេះកុមារនឹងឈានចាប់ពត៌មានកាន់តែប្រសើរថែមទៀតហើយដែនពិសោធន៍របស់កុមារក៏ត្រូវបានពង្រីក និងមានគំនិតកាន់តែសម្បូរបែបទូលំ ទូលាយ ។

វិញ្ញាណទាំង៥ ដើរតួរដូចជាប្រដាប់សម្រាប់ទទួលពត៌មានដូចជាអង់តែនមួយដែលផ្តល់លទ្ធភាពឱ្យយើងចាប់និងទទួលពត៌មានផ្សេងៗពីខាងក្រៅវិញ្ញាណទាំង៥ មិនគ្រាន់តែជួយប្រាប់យើងឱ្យដឹងអំពីអ្វី ដែលកើតឡើងជុំវិញខ្លួនប៉ុណ្ណោះទេតែនៅជួយបង្គ្រោះថ្នាក់ផ្សេងៗកុមារតូចទទួលពត៌មានពីខាងក្រៅតាម រយៈវិញ្ញាណទាំងប្រាំរបស់ខ្លួនប៉ុន្តែជាការពិតណាស់កុមារតូចពុំទាន់មានសមត្ថភាព ធ្វើការបកស្រាយពីវេទនាអារម្មណ៍ (ការដឹងដោយវិញ្ញាណ) របស់ខ្លួនបានច្បាស់លាស់ទេព្រោះវិញ្ញាណទាំងនេះពុំទាន់បានដុសខាត់នៅឡើយ ។ កុមារចាប់បានសូរសំលេង ក្លិន រូបភាពផ្សេងៗ ប៉ុន្តែកុមារពុំទាន់អាចចេះញែកសូរសំលេង ក្លិន រឺរូបភាពផ្សេងៗទាំងនេះឱ្យដាច់ស្រឡះពីគ្នាបានទេ ។ កុមារត្រូវការនូវឱកាសដ៏សមស្របក្នុងការស្វែងយល់ដោយសេរី រួមទាំងការពិសោធន៏ដោយផ្ទាល់ទៅលើវិញ្ញាណរបស់ខ្លួននោះហើយដែលកុមារអាចយល់ និងអាចញែកឱ្យឃើញពីភាពខុសៗគ្នានៃអ្វីៗទាំងអស់ដែលស្ថិតនៅជុំវិញខ្លួនបានល្អ ។ ការចេះសង្កេតមើល ការចេះស្តាប់ ការចេះហិតក្លិន ការចេះស្ទាប់សុទ្ធសឹងជាសម្បទាដែលត្រូវមានយ៉ាងចាំបាច់បំផុត ដើម្បីឈានទៅធ្វើការអភិវឌ្ឍរាល់ចំណេះដឹងទាំងនេះ ។

- ចលនាដៃ

ការធ្វើអ្វី១ដោយផ្ទាល់ដៃគឺជាវិធីមួយដ៏សំខាន់ដែលផ្តល់លទ្ធភាពឱ្យកុមារទទួលបាននូវ ភាពច្បាស់ការយ៉ាងល្អបំផុតលើចលនាផ្សេង១របស់ខ្លួននិងធ្វើឱ្យចលនាទាំងនោះមានសភាពកាន់តែជាក់លាក់ឡើង១។ នៅពេលដែលកុមារធ្វើចលនាបានកាន់តែទន់ភ្លន់ល្អនៅពេលនោះកាយវិការរបស់កុមារក៏មានសភាពកាន់តែជាក់លាក់និងសម្របសម្រួលគាបានកាន់តែប្រសើរហើយ កុមារក៏នឹងទទួលបាននូវភាពកាន់តែងាយ ស្រួលក្នុងការហាត់រៀនសំណេរក្នុងថ្នាក់ទី១ នៃសាលាបឋមសិក្សា។

- សញ្ញាណស្តីពីលំហ និងពេលវេលា (ផ្នែកបញ្ញា)

សញ្ញាណស្តីពីលំហ និងពេលវេលាប្រមូលផ្តុំរាល់សកម្មភាពទាំងឡាយដែលក្នុងនោះ កុមារត្រូវបានណែនាំឱ្យយល់ពីរាង ធរណីមាត្រផ្សេង១ ឱ្យកុមារបង្ហាញពីទីតាំងរបស់ខ្លួន និងទីតាំងរបស់វត្ថុនានាក្នុងលំហនិងក្នុងពេលវេលា។តាមរយៈការធ្វើសកម្មភាពផ្សេង១របស់ខ្លួនកុមាររៀនពីកាល ពេលជាបណ្តើរ១ ដោយការប្រើប្រាស់ពាក្យបញ្ជាក់ពីទំនាកទំនងជាមួយនិងពេលវេលាយ៉ាងសមហេតុសមផល។
ផ្តើមចេញពីលំហរមួយដែលខ្លួនធ្លាប់ស្គាល់រួចហើយ កុមារនឹងឈានទៅចាប់យកចំណេះដឹង ស្តីពីលំហរដទៃទៀតដែលមានភាពកាន់តែទូលាយឡើង១ កុមាររៀនធ្វើម្ចាស់ការ(រៀនប្រើប្រាស់ឱ្យបានត្រឹមត្រូវ ) ខាងលើ ខាងក្រោម នៅជិត ឆ្ងាយ។

- សមត្ថភាពសមហេតុផល (ផ្នែកបញ្ញា)

ប្រមូលផ្តុំរាល់សកម្មភាពធ្វើការជ្រើសរើសនិងសកម្មភាពរៀបចំដាក់ជាក្រុម១ (ឧទាហរណ៏ៈ ជ្រើសរើសនិងដាក់គ្រាប់អង្កាំជាក្រុម១របស់វាជ្រើសរើសនិងដាក់វត្ថុផ្សេង១ជាក្រុមដោយយោងទៅតាមការ ដែលគេអាចប្រើប្រាស់វាបាន)។

- បរិមាណ និងចំនួន (ផ្នែកបញ្ញា)

ប្រមូលផ្តុំរាល់សកម្មភាពដែលធ្វើ វីរៀបចំដោយដៃដែលទាក់ទងនិង បរិមាណ របស់វត្ថុផ្សេង១ទៀតនិងសកម្មភាពធ្វើការប្រៀបធៀបរវាងបរិមាណហើយនិង បរិមាណ (ឧទាហរណ៏ៈ បង្ហាញឱ្យកុមារឃើញនូវសំណុំវត្ថុមួយចំនួនរួចសួរកុមារថាតើសំណុំមួយណាដែលមានវត្ថុច្រើនជាងគេនិងតិចជាងគេ?)រួមបញ្ចូលសកម្មភាពរាប់ថែមទៀតផង។

តាមរយៈការធ្វើសកម្មភាពទាំងនេះកុមារមិនត្រឹមតែបានណែនាំឱ្យស្គាល់ខ្លួនឯងកាន់តែច្បាស់ថែមទៀតប៉ុណ្ណោះទេ កុមារអាចបង្កើនសមត្ថភាព ធ្វើទំនាក់ទំនងជាមួយកុមារដទៃក៏ដូចជាបរិស្ថានជុំវិញខ្លួនគេ។

## ២.២ តួនាទីសាលាមត្តេយ្យ

តួនាទីរបស់មត្តេយ្យសិក្សាគឺរួមចំណែកជួយដល់ការអភិវឌ្ឍរបស់កុមារនៅក្នុងគ្រប់ផ្នែកទាំងអស់បានសេចក្តីថាមត្តេយ្យសិក្សាមានតួនាទីផ្តល់លទ្ធភាពឱ្យកុមារមានឱកាសបន្តការរីកចម្រើនខ្លួនឯងផ្ទាល់បានកាន់តែច្បាស់ឡើងបានពង្រីកសមត្ថភាពរបស់ខ្លួនក្នុងការធ្វើទំនាក់ទំនងជាមួយកុមារដែលនឹងធ្វើសកម្មភាពជាមួយនឹងបរិស្ថានរបស់ខ្លួន ។

តួនាទីរបស់មត្តេយ្យសិក្សាគឺជាការតម្រង់ទិសឆ្ពោះទៅរកការអប់រំគ្រប់ផ្នែកនិងជាក់ស្តែងមួយតាមរយៈការអនុវត្ត គរុកោសល្យផ្តោតសកម្មភាព និងការធ្វើទំនាក់ទំនងដែលផ្តោតចំពោះកុមារ ។

ពោលគឺជាការជួយកុមារឱ្យ:

- រស់នៅបានដោយពេញលេញ
- អភិវឌ្ឍបំណិនផ្សេងៗជាមូលដ្ឋានរបស់ខ្លួន

  សមត្ថភាពក្នុងការសង្កេតក្នុងការរក្សាការយកចិត្តទុកដាក់

  ការធ្វើទំនាក់ទំនងក្នុងការកំណត់ចំណុចគោលរបស់ខ្លួននៅក្នុងពេលវេលាក្នុងលំហ (ក្នុងការចងចាំប្រៀប ធៀប ដាក់ ទំនាក់ទំនងរៀបចំ.....)
- កសាងបុគ្គលិកលក្ខណៈរបស់ខ្លួន

និយាយឱ្យខ្លីនៅមត្តេយ្យសិក្សាគេរៀបចំកុមារដើម្បីត្រៀមខ្លួនឆ្ពោះទៅរកការហាត់រៀននៅសាលាបឋមសិក្សានាពេលអនាគត គឺប្រៀបដូចជាអ្នកតម្បាញម្នាក់ដែលត្រូវរៀបចំអំបោះសម្រាប់ចាក់ឱ្យហើយស្រេចជាមុននឹងចាប់ផ្តើមត្បាញដូច្នោះដែរ ។ទន្ទឹមនឹងនេះសាលាមត្តេយ្យក៏មានតួនាទីរៀបចំកុមារឱ្យមានចំណង់ក្នុងការរៀន ។ យោងតាមការពណ៌នាខាងលើដើម្បីរៀបចំកុមារឱ្យត្រៀមខ្លួនឆ្ពោះទៅរកការរៀនថ្នាក់ទី១ នៅបឋមសិក្សាប្រកបដោយប្រសិទ្ធភាព នោះគ្រូគប្បីយល់ដឹងឱ្យបានច្បាស់ពីចិត្តវិទ្យាចិត្តគរុកោសល្យរបស់កុមាររួមជាមួយនឹងការយកចិត្តទុកដាក់លើការបង្រៀនគ្រប់ផ្នែក ពិសេសគឺភាសាសរសេរនេះឯង ។

## ២.៣ ទស្សនៈរបស់គរុវិទូលើកុមារ

ក្នុងការស្រាវជ្រាវ តម្រូវឱ្យមានដកស្រង់នូវទស្សនៈជាច្រើនដែលទំនាក់ទំនងទៅនឹងសារៈសំខាន់របស់មត្តេយ្យសិក្សា ។

ក្នុងនោះផងដែរ ទស្សនៈរបស់គរុវិទូជាច្រើនបានបង្ហាញទស្សនៈរបស់ខ្លួនដូចខាងក្រោម សមាជិកបណ្ឌិតសភាជាតិសូវៀតឈ្មោះ **នីកូឡៃអាម៉ាសូវ** អត្តចរិតរបស់កុមាររីកលូតលាស់ពីរភាពបីក្នុងរយៈពេល៣ឆ្នាំគឺចាប់ពីអាយុ៣ឆ្នាំដល់៦ឆ្នាំ ។ រីឯអត្តចរិតមួយភាគទៀតលូតលាស់ក្នុងរយៈ

ពេល១១ឆ្នាំគឺចាប់ពីអាយុ៦ឆ្នាំដល់អាយុ១៧ឆ្នាំ ។ការបង្ហាញនៅទស្សនៈនេះឃើញថាក្នុងវ័យមត្តេយ្យសិក្សា កុមារផ្តិតយក ការអប់រំបានឆាប់រហ័សណាស់ ។

- ចិត្តវិទូនាយុគសម័យយើងនេះ " កុមារប្រក្រតីចាប់មានបុគ្គលិតលក្ខណៈពីអាយុ ៣ឆ្នាំត្រូវតែឆ្លងកាត់ដំណាក់ការលូតលាស់មួយយ៉ាងវែង រហូតដល់យុវ័យទើបបុគ្គលិកលក្ខណៈនោះ មានទម្រង់ជាគ្រឹះពេញលេញ " ។ ហេតុដូចនេះហើយទើបគេចាត់ទុកដំណាក់កាលវ័យកុមារមត្តេយ្យនេះជាលំនាំកំណក់កំណើតបុគ្គលិកលក្ខណៈមនុស្សជាកំណាក់ដំបូងនិងជារបត់កំណក់កំណើតបុគ្គលិកលក្ខណៈ ។

- លោក **ហ្សង់ហ្សាក់រូស្ស Jean Jacque Rousseau ( 1712-1778 )** គរុវិទូបារាំង : មនុស្សកើតមកសុទ្ធតែ ល្អគឺសង្គមជាអ្នកធ្វើអោយឱ្យគេក្លាយទៅជាអាក្រក់ ។ តាមទស្សនៈនេះគាត់ណែនាំឱ្យធ្វើការអប់រំអភិវឌ្ឍមនុស្សក្នុងមនុស្ស គឺអប់រំដោយគោរពបុគ្គលិកលក្ខណៈរបស់កុមារ អ្នកអប់រំត្រូវស្គាល់ចិត្តសាស្ត្រកុមារនិងការលូតលាស់របស់កុមារច្បាស់លាស់នោះ ទើបអាចសម្របសម្រួលវិធីសាស្ត្រអប់រំរបស់ខ្លួនសមស្របនឹងកម្រិតរបស់កុមារ ។

- តាមឯកសារចិត្តវិទ្យា និងការបញ្ចាំង **Video** របស់បណ្ឌិត **អ៊ឹម កុច** បានបង្ហាញឱ្យឃើញថា "កុមារអាចប្រៀបធៀបគ្នាបានតាមអាយុបង្រៀនអ្វីឱ្យស្របនឹងអាយុរបស់កុមារ បើបង្រៀនហួសអាយុ ធ្វើឱ្យបញ្ញាញាណ របស់កុមារត្រូវក្រិន" ។ ហេតុនេះហើយ ការបង្រៀននៅមត្តេយ្យសិក្សាពិសេសភាសាសរសេរត្រូវឱ្យស្របតាម អាយុនិងការលូតលាស់បុគ្គលិកលក្ខណៈរបស់កុមារ ។ ក្នុងនោះផងដែរការគិតរបស់កុមារមានលក្ខណៈខុសពីមនុស្សធំដែរ ។ការរៀនរបស់កុមារចេញពីការសង្កេតឈានទៅរកគំនូរបន្ទាប់មកឈានទៅរកការអភិវឌ្ឍភាសា ។ដូចនេះដើម្បីឱ្យកុមារនៅ មត្តេយ្យសិក្សាកម្រិតខ្ពស់អាចរៀនរប្រៀបសរសេរបានលោកគ្រូអ្នកគ្រូត្រូវស្គាល់ឱ្យបានពីលក្ខណៈ និងអាយុរបស់កុមារទើបការបង្រៀនទទួលបាននូវជោគជ័យ ។

## ២.៤ ចិត្តវិទ្យាកុមារ

### ក. អភិវឌ្ឍរូបរាងកាយ និងសុខភាព

កុមារមិនគ្រាន់តែធំធាត់ឡើងតែវ័យ ទំងន់ ទំហំ និងកំពស់តែការរីកចំរើនឡើងនៃរាងកាយនេះសមត្ថភាពផ្នែកចលកររបស់កុមារក៏ត្រូវបានអភិវឌ្ឍផងដែរ ។កុមាររកឃើញនិងយល់ដឹងពីអ្វីៗដែលនៅជុំវិញតាមរយៈការសម្របសម្រួលនៃវិញ្ញាណទាំង៥ និងដោយសារភាពម្ចាស់ការរបស់ខ្លួនដែលមានលក្ខណៈកាន់តែប្រសើរឡើងជាលំដាប់ទៅលើចលនាផ្សេងៗដែលខ្លួនធ្វើ ។ តាមរយៈល្បែងកុមារសិក្សាស្វែងយល់និងស្គាល់ពីរាងកាយកាន់តែច្បាស់ ហើយកុមារនឹងទទួលបាននូវការសម្របសម្រួលមួយយ៉ាងប្រសើរកុមារធ្វើការរ៉ឹកហាត់ដើម្បីគ្រប់គ្រងលើលំនឹងរបស់ខ្លួន ។ ការរត់

លូន ដើរ លោត គឺសុទ្ធសឹងជាកាយវិការដែលផ្តល់លទ្ធភាពឱ្យកុមារក្លាយទៅជាមនុស្សម្នាក់ ដែលកាន់តែមានប៉ិនប្រសប់ ។

**ខ. សីលធម៌ និងវប្បធម៌**

កុមារចេះទំនាក់ទំនងក្នុងមជ្ឈដ្ឋានខាងក្រៅ ក៏ដូចជាយល់នូវទំនៀមទំលាប់របស់ជាតិសាសន៍ និងអត្តសញ្ញាណរបស់ខ្លួន ។ ចេះគោរពចាស់ព្រឹទ្ធាចារ្យ ឪពុក-ម្តាយ ញាតិមិត្ត ។

**គ. ការអភិវឌ្ឍ សង្គមអារម្មណ៍**

នៅអាយុ៣ឆ្នាំកុមារមានលទ្ធភាពទប់នឹងសម្របសម្រួលចលនា និងសញ្ចេតនារបស់ខ្លួនបានកាន់តែប្រសើរ ។ ទំនាក់ទំនងជាមួយអ្នកដ៏ទៃក៏មានលក្ខណៈសមរម្យជាងមុន ។ អត្តទត្តនិយម និងតម្រូវការផ្ទាល់ខ្លួនត្រូវ បានថយចុះ ។ កុមារចាប់ផ្តើមចេះប្រើពាក្យ " នឹង " ដល់អាយុ ៤ឆ្នាំ កុមារតែងមានគំនិតធ្វើអ្វីៗតាមទំនើងចិត្តតាមតែការនឹកឃើញ កុមារក្មេងក្អេង ហើយចង់ឱ្យអ្នកដ៏ទៃទទួលស្គាល់ខ្លួនគេថាជាមនុស្សមួយរូបដែរ ។ ក្នុងឋានៈជាភាវៈសង្គមមួយកុមារចាប់អារម្មណ៍យ៉ាងខ្លាំងក្លាទៅលើពាក្យ " ព្រោះអ្វី **?** " , " យ៉ាងដូចម្តេច **?** " ដល់អាយុ ៥ ឆ្នាំកុមារមានលំនឹងផ្នែកបុគ្គលខ្លួនឯង និងសង្គមកុមារហាក់បានយល់ច្បាស់ពីខ្លួនឯងហើយតែងសំដែងភាពស្និទ្ធ ស្នាលនឹងពិភពជុំវិញដែលហាក់ដូចជាថ្មីថ្មោងចំពោះខ្លួន ។

ក្នុងទំនាក់ទំនងសង្គម ពិសេសនៅក្នុងផ្ទះកុមារបានប្រើចំណេះដឹងរបស់ខ្លួនអស់លទ្ធភាពក្នុងករណីចាំបាច់កុមារតែងហៅរកមនុស្សចាស់ឱ្យជួយគេ ។កុមារតែងស្វែងរកការសប្បាយរីករាយដោយសារជោគជ័យរបស់ខ្លួន និងការយល់ព្រមពីសង្គមផងដែរ ។ កុមារតែងជឿជាក់លើខ្លួនឯងហើយមិនអាចយកតាមទស្សនៈអ្នកដទៃឡើយ ។

**ឃ- ការអភិវឌ្ឍបញ្ញាស្មារតី**

កុមារមានការលូតលាស់ផ្នែករាងកាយ ទន្ទឹមគ្នានឹងការរីកលូតលាស់ផ្នែកបញ្ញាស្មារតីដែរ ។ ក្នុងនោះការលូត លាស់ផ្នែកខួរក្បាលគួរឱ្យចាប់អារម្មណ៍ គឺកុមារដែលកើតភ្លាមមានទម្ងន់ខួរក្បាល ៣០០g ពេលអាយុបាន១ឆ្នាំ ទម្ងន់ខួរក្បាលកើតឡើងពី ៨០០g - ៩០០g ។ លុះអាយុបាន ៦ឆ្នាំឡើងដល់ ១២៤០g និងអាយុពេញវ័យទម្ងន់ខួរ នេះកើនឡើងរហូតដល់ ១៥០០g ។ ការរីកលូតលាស់ផ្នែកខួរក្បាលនេះ ជំរុញឱ្យកុមារលូតលាស់ផ្នែកបញ្ញា ដែលគេ អាចចែកជាដំណាក់ ( តាមទ្រឹស្តីរបស់លោក **ពីយ៉ាសេ Piaget** )

- ដំណាក់ឥន្ទ្រីយ៍ចលករពី ០ ទៅ ២ឆ្នាំ
- ដំណាក់បុរេប្រតិបត្តិពី ២ ទៅ ៧ឆ្នាំ

- ដំណាក់ប្រតិបត្តិពី ៧ ទៅ ១០ឆ្នាំ
- ដំណាក់រៀបរយពី ១២ឆ្នាំឡើងទៅ

ដំណាក់នីមួយៗមានគុណភាពប្លែកៗគ្នា ហើយសុទ្ធតែបង្ហាញពីអន្តរកម្មនៃកត្តាទាំងឡាយដែលផ្សារភ្ជាប់ទៅនឹងមជ្ឈដ្ឋានជុំវិញគ្រួសារសាលារៀន ។ហេតុនេះដំណាក់នីមួយៗ តែងបង្ហាញឱ្យឃើញនូវការសម្របថ្មីរបស់កុមារម្នាក់ៗទៅនឹងមជ្ឈដ្ឋានសង្គម ។ ជាការសន្និដ្ឋាន លោក **ពីយ៉ាសេ្យ Piaget** កំណត់ថាប្រតិកម្មបញ្ញាគឺជាការសម្របសម្រួលបានន័យថាក្នុងកំណាក់បុរេបញ្ញាកុមារមានបញ្ញា គឺកុមារដែលមានសមត្ថភាពសម្របទៅនឹងស្ថានភាពថ្មីមួយបាន ។

ក្រៅពីការអភិវឌ្ឍបញ្ញា កុមារត្រូវការអភិវឌ្ឍបញ្ញាសមត្ថភាពច្រើនទៀត ។

**ង.ការលូតលាស់គំនិត និងភាសារបស់កុមារ**

បទពិសោធមួយក្នុងចំណោមបទពិសោធគួរឱ្យយកចិត្តទុកដាក់បំផុតដែលយើងអាចធ្វើបានដូចជាឪពុកម្តាយ និងអ្នកអប់រំនោះគឺបទពិសោធចូលរួមក្នុងលំនាំនៃការលូតលាស់ភាសារបស់កុមារ ។ នៅក្នុងរយៈពេលមួយដ៏ខ្លីវាតែងតែមានអ្វីមួយមិនធម្មតាដែលលិចឡើងក្នុងលំនាំកុមារឆ្លងកាត់ពីភាពស្ងោត់ទៅរកការប្រាស្រ័យទាក់ទងដោយភាសា ។

ប៉ុន្តែតើកុមាររៀនឧបករណ៍មានអានុភាពនេះពោលគឺភាសាយ៉ាងដូចម្តេច? ការសិក្សាជាច្រើនបានបាញ់ឆ្ពោះទៅរកចំណុចនេះ ។ ការសិក្សាទាំងនេះបានផ្តល់ពតិមានសំខាន់ៗសម្រាប់ឱ្យយល់ពីទំនាក់ទំនងជិតស្និទ្ធរវាងការលូតលាស់ភាសា នឹងការលូទលាស់បញ្ញាព្រមទាំងការលូតលាស់បុគ្គលិកលក្ខណៈរបស់កុមារ ។ ពតិមានទាំងនោះក៏បានជួយយើងឱ្យយល់ផងដែរថាយើងអាចជំរុញបន្ថែមលើការលូតលាស់ភាសារបស់កុមារនៅក្នុងគ្រួសារ និងមជ្ឈដ្ឋានសាលារៀនយ៉ាងដូចម្តេច ?

**- ដំណាក់កាលមុនពេលរៀនភាសា ការចាប់យកពាក្យ**

វិវត្តន៍នៃភាសានិយាយរួមមានពីដំណាក់ :

ដំណាក់មុនពេលមនុស្សរៀនភាសាដែលចាប់ផ្តើមពីអាយុ 0 ដល់ ១ ឆ្នាំ និងដំណាក់រៀនភាសាដែលចាប់ ផ្តើមនៅអាយុចុងបញ្ចប់នៃឆ្នាំទី ១ ។

ដំណាក់មុនពេលរៀនភាសាត្រូវបានកំណត់យ៉ាងជាក់ច្បាស់ ដោយលំហាត់និយាយអមដោយកាយវិការ ( យំ ហាត់ច្រៀង បង្កើតពាក្យ ដោយផ្ទំយកតាមសំលេងដូចជាពាក្យតុកកែជីងចក់....) ។ បន្តិចម្តងៗ កុមារចាប់ផ្តើមបង្កើតទំនាក់ទំនងរវាងសូរដែលវាលឺនិងសូរដែលវាបានបង្កើតឡើង ។ កុមារកាន់តែឆាប់ចាប់បាន ភាពខុសគ្នារវាងមូលស័ទ្ទ ( ឧទាហរណ៍ :

ភាពខុសគ្នារវាង " ក " និង " គ " ហើយចំពោះការគ្រាប់តាម និងការ រកឃើញកុមារចាប់ផ្តើមបង្កើតពាក្យ ។

ដំបូងកុមារមិនទាន់ស្គាល់ទំនាក់ទំនងរវាងសូរនិងន័យទេ។បន្តិចម្តងៗ កុមារចាប់ផ្តើមយល់ដឹងខ្លួនឯងពីសូរខ្លះៗគេស្គាល់និងអាចបភ្លឺដោយមានន័យនិងរួមបញ្ចូលដោយផ្សារភ្ជាប់ទៅនឹងស្ថានការណ៍វត្ថុនិងអំពើជាក់លាក់។ កុមារយល់ដឹងពីទំនាក់ទំនងហេតុផលរវាងបន្សាយសំលេងនិងទង្វើខ្លះៗរបស់ខ្លួន។ ទន្ទឹងនឹងការចាប់យក ពាក្យ កុមារក៏ចាប់ផ្តើមបញ្ចេញគំនូសរបស់គេដែរ ។

**- ដើមដំបូងនៃការបញ្ចេញគំនូស**

តាមន័យដើម គំនូសគឺជាផលវិបាកមួយនៃកាយវិការឯកឯងរបស់កុមារដែលបន្សល់ទុកស្នាមមួយដូចជាកុមារអូសដៃក្នុងចានបបរ គេគូសក្រវេមក្រវាមនៅលើជញ្ជាំងគេយកក្រេមលាបមាត់ឬម្សៅទៅប៉ាតលើកញ្ចក់ឬជញ្ជាំងបន្ទាត់។ល។កុមារអាយុប្រមាណ១ឆ្នាំតែងចូលចិត្តគូសតាមទំនើងចិត្ត ។ សកម្មភាពល្បែងនេះបណ្តាលមកពីតម្រូវការផ្នែកចលនាដែលមិនអាចបង្ក្រាបបានផង និងស្របទៅតាមការសប្បាយជាក់ស្តែងរបស់គេផង ។

លុះអាយុ ១៨ទៅ ២៤ខែ គំនូសក្រវេមក្រវាមនេះ ត្រូវបានរៀបរយជាបណ្តើរៗទីបំផុតកុមាអាចគូសខ្សែ បានច្រើនប្រភេទ ។

## ២.៥ ចំណេះដឹងមានស្រាប់របស់កុមារមុននឹងចូលសាលារៀន

កុមារចាប់ពីកើតរហូតដល់អាយុ១៥ខែ ខួរក្បាលរបស់គេសម្រាប់តែរស់ប៉ុណ្ណោះ ហើយជាដំណាក់កាលអភិវឌ្ឍវិញ្ញាណទាំងប្រាំរយៈកាលនេះ កុមាររីកលូតលាស់ចម្រើនផ្នែករាងកាយចេះដើរនិងលូតលាស់ប្រព័ន្ធចិត្តរំភើប(សញ្ចេតនា)និងភាសាហើយជារយៈកាលដែលកុមារ
ផ្សាំខ្លួនទៅនឹងសង្គម ។

- កុមារអាយុ ៤ឆ្នាំ ទៅ៧ឆ្នាំ ចលនារបស់គេកាន់តែច្បាស់លាស់ ( ចំទិសដៅ ) កុមារអាចកាន់ខ្មៅដៃសម្រាប់សរសេររីកលូតលាស់ប្រព័ន្ធនៃចង្វាក់ ឈានទៅអភិវឌ្ឍភាសា គឺកុមារអាចនិយាយអ្វីដែលគេបានគិត បើមិន និយាយទេ គេនឹងភ្លេចទៅវិញ ( កុមារគិត ឃើញអ្វីនិយាយភ្លាម ) ។នៅក្នុងដំណាក់កាលនេះប្រព័ន្ធខួរក្បាលខាងស្តាំរីកលូតលាស់ គឺគេអាចចាប់យករូបភាពទាំងមូលបាន ។

-អាយុ៧ឆ្នាំឡើងទៅដំណើរការប្រព័ន្ធខួរក្បាលផ្នែកខាងឆ្វេងរីកលូតលាស់ គេអាចចាប់យកផ្នែកតូចៗល្អិតរួចឈានទៅរកការវិភាគមានតួនាទីប្រៀបធៀបអ្វីដែលដូចគ្នា អ្វីដែលខុសគ្នា ។ ដំណាក់កាលនេះ កុមារចេះធ្វើការពិចារណាមុននឹងនិយាយ ។ ប្រព័ន្ធខួរក្បាលខាងឆ្វេងនេះ

ជាផ្នែកមួយជាប់ទាក់ទងយ៉ាងខ្លាំងផ្នែកភាសា ។ ក្នុងនោះកុមារអាចមានសកម្មភាពប៉ាន់ស្មានវិទាយទុក ។

-អាយុ៩ដល់១២ឆ្នាំទំនាក់ទងនៃប្រព័ន្ធទាំងពីរច្បាស់លាស់មែនទេនខួរក្បាលវាអាច ផ្សារភ្ជាប់គ្នាបានក្នុងល្បឿនការគិត ។ សារធាតុម្យ៉ាងស្រោបកោសិកាខួរក្បាលពេញលេញ ។

ដូចនេះក្នុងអំឡុងអាយុ៦ឆ្នាំគេមិនអាចបង្ខំកុមារឱ្យធ្វើកិច្ចការហួសសមត្ថភាពរបស់គេទេ គឺធ្វើឱ្យកុមារមិនចង់ទៅសាលារៀន។ ខួរក្បាលកុមាររីកលូតលាស់ដូចគ្នាតែពេលវេលានៃការលូតលាស់មិនដូចគ្នាទេគឺកុមារខ្លះស្ពឹកធ្វើឱ្យកុមារនោះមិនសូវសម្បូរភាសា ឯកុមារខ្លះមានភាពឆ្លាតដោយខួរក្បាលគេឆាប់លូតលាស់ ។ ក្នុងលក្ខណៈនេះបង្ហាញថា កុមារមុននឹងចូលសាលារៀនគេមានបុរេពុទ្ធិរួចហើយ ។

**តើកុមារអាយុ៦ឆ្នាំត្រៀមខ្លួនដូចម្តេចខ្លះ ដើម្បីចូលសាលារៀនបឋមសិក្សា ?**

១ - សមត្ថភាពស្តាប់

កុមារអាចស្គាល់សម្លេងទាប-ខ្ពស់ និងព្យែកសូរ សំនៀងវែងខ្លី ហើយចេះរកប្រភពសម្លេង ( ផ្តោតអារម្មណ៏លើសម្លេងណាដែលបានស្តាប់) ។កុមារមានសមត្ថភាពលេងជាមួយសូរទាំងអស់ដែលគេបានស្តាប់ដូចជា ធ្វើត្រាប់តាមសូរឆ្កែព្រូស ឆ្មាយំ មាន់ខ្ពត ជាដើម ។ មិនតែប៉ុណ្ណោះគេអាចចេះដកសម្លេង រឺបន្ថែមសម្លេងទៅ លើពាក្យនោះ រឺផ្នែកផ្សេងៗនៃសូរ ( ឧទាហរណ៏ : ខ្យង បង ....... ) ពេលគ្រូច្រៀង កុមារអាច ស្តាប់ដឹងពីចំនួន ព្យាង្គរបស់ពាក្យ ។ កុមារមានបំរុងប្រយ័ត្នក្នុងការស្តាប់ ដើម្បីធ្វើឱ្យដូចគំរូដើម ដូចជាគេ អាចស្តាប់ហើយចងចាំការណែនាំរួចនិយាយឡើងវិញតាមលំដាប់ចាស់ ។

២ - សមត្ថភាពការរកឃើញតាមភ្នែក

កុមារពេលឃើញរូបលំអិត ជាតួនាទីរបស់អឌ្ឍគោលខួរក្បាលខាងឆ្វេង ។ ពេលឃើញរូបទាំងមូលជាតួនាទីអឌ្ឍគោលខួរក្បាលខាងស្តាំ។ ដូចនេះគ្រូត្រូវធ្វើឱ្យសាច់ដុំភ្នែករបស់កុមារដំណើរការបានល្អដោយរៀបចំល្បែងរៀបរូបផ្គុំគូរផាត់ពណ៌ផាត់ផែនទី ធ្វើយ៉ាងណាឱ្យកុមារមើលឃើញតាមរយៈភ្នែកបានល្អដែលអាចឈានទៅរកការសរសេរ។ ត្រូវហ្វឹកហាត់តាំងពីតូចនូវការថតរូបនឹងភ្នែកដើម្បីចូលក្នុងខួរក្បាលរបស់គេ។ ការបង្ហាញឈ្មោះរបស់គេតាមរយៈគំនូសអក្សរធ្វើឱ្យកុមារស្គាល់ទ្រង់ទ្រាយឈ្មោះរបស់គេ ហើយអាចធ្វើឱ្យកុមារស្គាល់ ពាក្យបង្កើតពាក្យតាមរយៈភាសានិយាយហើយឈានទៅដល់ការរៀនភាសាសរសេរ ។

៣ –សមត្ថភាពផ្នែកភាសា

កុមារមត្តេយ្យ មិនទាន់មានសមត្ថភាពក្នុងការបំភ្លឺពាក្យឱ្យបានត្រឹមត្រូវទេ ដូចនេះកុមារក៏មិនអាចចេះសរសេរពាក្យឱ្យបានត្រឹមត្រូវដែរ ។ប៉ុន្តែគប្បីណែនាំកុមារឱ្យចេះនិយាយឱ្យបានពេញឃ្លា គឺមិនត្រូវនាំកុមារឱ្យនិយាយពាក្យកាត់ៗទេ( ឧទាហរណ៏ ដូចជាគ្រូសួរទៅកុមារថា៉ តើកូនឃ្លានបាយទេ **?** ”) កុមារឆ្លើយថា ” **ឃ្លាន** ” គ្រូត្រូវណែនាំកុមារឱ្យឆ្លើយថា ” ចាស រឺបាទ អ្នកគ្រូខ្ញុំឃានបាយ ” ការនិយាយបែបនេះធ្វើឱ្យកុមារអភិវឌ្ឍបាននូវភាសានិយាយ ដែលជាគ្រឹះនៃភាសាសរសេររបស់ កុមារ ។

ក្រៅពីអភិវឌ្ឍភាសា ត្រូវឱ្យកុមារបញ្ចេញនូវសញ្ចេតនារំភើបរបស់ខ្លួនប្រាប់អ្នកដទៃ គឺចេះបង្ហាញពាក្យដែលមានក្នុងចិត្តប្រាប់ទៅអ្នកដទៃព្រោះថាកុមារមិនអាចរៀនបានទេនៅពេលដែលខួរក្បាលរបស់គេមានអ្វីដក់ជាប់នៅក្នុងខ្លួននោះ ។ សាលារៀនជាកន្លែងមួយឱ្យកុមារបញ្ចេញនូវអ្វីដែលគេចង់និយាយដោយសេរី ។គ្រូមានភារកិច្ចជាអ្នកអប់រំត្រូវបង្កបរិយាកាសយ៉ាងណាឱ្យកុមារបានបញ្ចេញមតិបានអានតាមរាប់តាម និងរីករាយ សប្បាយជានិច្ចផងដែរ ។

## តើអ្វីជាបទពិសោធ កុមារចូលសាលារៀនបឋមសិក្សា អាចធ្វើបាន ?

ក្រោមឥទ្ធិពលនៃការងាររបស់លោក Blenkin and Kelly(1992), Good(1977) and Gull(1994).ផ្អែកតាមអ្នកនិពន្ធទាំងនេះការកំណត់គោលបំណងនៃការវាយតំលៃទៅ លើសិស្សសាលាគឺដើម្បីកំណត់ការអភិវឌ្ឍន៏សមត្ថភាពរបស់ពួកគេ រឺក៏កំណត់នូវចំណេះដឹង រឺជំនាញរបស់កុមារដែលទទួលបាន ពីលទ្ធផលនៃបទពិសោធន៏ការអប់រំកុមារតូច ។

គឺគេធ្វើឡើងដើម្បីរកឱ្យឃើញថាកូនសិស្សថ្នាក់ទីមួយទាំងនោះអាចធ្វើបាន រឺមិនបានទៅលើបរិបទខាងក្រោមនេះ:

១. បញ្ជាក់ឈ្មោះរបស់ពួកគេត្រឹមត្រូវ
២. អាចបញ្ជាក់ផ្នែកផ្សេងៗនៃរាងកាយរបស់ពួកគេ
៣. ធ្វើបានតាមការចង្អុលបង្ហាញងាយៗ( ដូចជាទះដៃជាដើម)
៤. រាប់ចំនួនពី១ ទៅដល់ ១០
៥. ស្គាល់ចំនួនច្បាស់ពី ១ ទៅ ១០
៦. អាចផ្គូផ្គងរបស់ ទៅនឹងចំនួនជាលេខ
៧. កំណត់បាននូវលក្ខណៈធរណីមាត្ររបស់វត្ថុផ្សេងៗក្នុងថ្នាក់រៀន
៨. បញ្ជាក់ពីពណ៌ផ្សេងៗគ្នាយ៉ាងហោចណាស់បាន៥
៩. កំណត់បាននូវពណ៌របស់វត្ថុនានានៅក្នុងថ្នាក់រៀន
១០. រៀបរាប់បាននូវអក្សរ៥ដំបូងនៃអនក្ខរកម្ម

១១. រៀបតាមប្រភេទផ្សេងៗនៃកាក់ទាំងឡាយ ដោយផ្អែកលើរូបភាពដែលផ្តល់ឱ្យ

១២. តំរៀបនូវវត្ថុនានាពីស្រាលទៅធ្ងន់ រឺពីធ្ងន់ទៅស្រាល

១៣. តំរៀបវត្ថុផ្សេងៗតាមប្រវែងរបស់វា

១៤. ប្រៀបធៀបវត្ថុផ្សេងៗ

១៥. រកឃើញលក្ខណៈខុសគ្នារវាងវត្ថុនានា

ចំណុចទាំង១៥ខាងលើ ក៏ជាឧបករណ៍វាយតម្លៃដែលរួមបញ្ចូលដោយសំណួរ៥ ផ្នែកគណិត ៥ផ្នែកភាសាអងគ្លេស់ និង៥ទៀតផ្នែកវិទ្យាសាស្ត្រ។

ដោយផ្អែកលើបរិបទខាងលើនេះដែរ ក៏ក្លាយទៅជាឧបករណ៍វាយតម្លៃមួយ ក្នុងប្រទេសបូស្វាណា ដែលធ្វើលើឡើងដោយសន្មតទៅភាពដូចគ្នារវាងការសិក្សាថ្នាក់មត្តេយ្យនិង សមិទ្ធិផលក្នុងថ្នាក់បឋមសិក្សា។ការសិក្សាស្រាវជ្រាវនេះតំរង់ទិសសម្រាប់រកឱ្យឃើញថាតើវាពិតជាមានភាព ខុសប្លែកគ្នារវាងសិស្សថ្នាក់ទី១ក្នុងប្រទេសបូស្វាណា ដែលបានឆ្លងកាត់មត្តេយ្យ និងសិស្សដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សាដែររឺអត់? ដែលគេបានកំណត់នូវមុខវិជ្ជាជាក់លាក់សំរាប់សិក្សានោះ រួមមានភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថាកូនសិស្សដែលបានឆ្លងកាត់មត្តេយ្យសិក្សា បានយកឈ្នះលើកូនសិស្សដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សា ទៅលើគ្រប់មុខវិជ្ជាទាំងបីដែលបានសិក្សាស្រាវជ្រាវ ។អត្ថបទនេះបានសង្ខេបដែរទៅការអង្កេតការអប់រំសិស្សថ្នាក់មត្តេយ្យដែលមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ដើម្បីធ្វើយ៉ាងណាឱ្យជំនាញ ដែលត្រូវឱ្យមានជាមុនរបស់សិស្សានុសិស្សទាំងនោះងាយស្រួលក្នុងការចាប់យក។

លទ្ធផលនៃការស្រាវជ្រាវបានឱ្យគំនិតថា កូនសិស្សដែលចូលសិក្សាថ្នាក់បឋមដំបូងៗ មានភាពងាយស្រួលរៀបចំសម្រាប់បរិស្ថានសាលារៀន ហើយពួកគេនិងអាចធ្វើកាន់តែប្រសើរទៅលើធនធានសាលារៀន ប្រសិនបើពួកគេបានសិក្សាឱ្យជ្រួតជ្រាបទៅលើមត្តេយ្យសិក្សាជាមុននោះសិន។ ការអប់រំមត្តេយ្យត្រូវបានគេដឹងលឺថាជាការផ្តត់ផ្តង់ទៅលើការអភិវឌ្ឍទៅលើជំនាញសង្គមជាមូលដ្ឋាននានា ព្រមទាំងកង្វះខាតដែលកូនសិស្សតូចៗទាំនោះគ្មានដូចជា ជំនាញ ហានិភ័យ " ការបដិសេធន៏ពីមិត្តភ័ក្រ " និង"បរាជ័យក្នុងការសិក្សា"។តាមរយៈការអង្កេតជាឧទាហរណ៍យើងឃើញថា សំរាប់សិស្សដែលបានឆ្លងកាត់មត្តេយ្យសិក្សា ពួកគេមានអារម្មណ៏នឹងធឹង ជាងកុមារដែលមិនបាន ឆ្លងកាត់មត្តេយ្យសិក្សា នៃថ្ងៃចូលរៀនពីរ បីថ្ងៃដំបូងរបស់គេនៅសាលា។ ជាងនេះទៅទៀតភាគច្រើននៃពួកគេទាំងនោះមិនសូវយំនិងទាមទារទៅផ្ទះ វិញនោះទេ។ ទាំងអស់នេះត្រូវបានគេដឹងថាគឺជា អន្តរភាពយ៉ាងរលូនចេញពី "ពិភពសង្គម" នៅឯផ្ទះ ទៅរក"ពិភពត្រឹមត្រូវ" នៅឯសាលា។

# ជំពូកទី៣

## ៣.១ ទំហំ និង វិធីសាស្ត្រនៃការស្រាវជ្រាវ

ក.វិធីសាស្ត្រជ្រើសរើសក្នុងការស្រាវជ្រាវ បែបគុណតម្លៃ ដោយផ្អែកលើគោលបំណងនឹងត្រូវយកមកប្រើប្រាស់ដើម្បីកំណត់យកកុមារដែលមានអាយុពី៥ដល់៦ឆ្នាំដែល បានឆ្លងកាត់មត្តេយ្យសិក្សា និងមិនបានឆ្លងកាត់នៅក្នុងថ្នាក់ទី១ឆមាសទី១។ សាលាបឋមសិក្សាចំនួនពីរ គឺសាលាបឋមសិក្សាស្អាង ដែលស្ថិតនៅក្នុងភូមិស្អាងឃុំកំពង់ថ្មស្រុកសន្ទុកនិង សាលាបឋមសិក្សាស្នោឃ្លេ ដែលស្ថិតនៅក្នុងភូមិស្នោ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ នឹងត្រូវជ្រើសរើសយកមកសិក្សាស្រាវជ្រាវ ។
ក្នុងនោះដែរ យើងជ្រើសរើសសិស្សចំនួន ៣៦នាក់ ដែលកំពុងរៀននៅថ្នាក់ទី១ ចំនួន២សាលា ហើយសិស្ស១៦ នាក់មិនបាន ឆ្លងកាត់មត្តេយ្យរដ្ឋ មត្តេយ្យសហគមន៍ ក៏ដូចជាមត្តេយ្យអប់រំតាមខ្នងផ្ទះនឹង ២០នាក់បានឆ្លងកាត់មត្តេយ្យសិក្សារដ្ឋ ដោយមានរយះពេល១៥នាទីក្នុងការសម្ភាសន៍ នឹងអង្កេតលើកុមារម្នាក់ៗ។

ខ.ឧបករណ៍វាយតម្លៃកុមារត្រូវបានជ្រើសរើសក្នុងកម្រងសំនួរស្តង់ដាសិក្សានិងអភិវឌ្ឍកុមារតូចនៅកម្ពុជា ។ ដែលក្នុងនោះមាន ៥វិស័យធំៗ :

-វិស័យទី១ ការអភិវឌ្ឍរូបរាងកាយនិងសុខភាព (ការអភិវឌ្ឍផ្នែកចលករ ការគាំពារផ្នែកសុខភាព បំណិនសុវត្ថិភាព)។

-វិស័យទី២ ការអភិវឌ្ឍសីលធម៌និងវប្បធម៌(យល់ដឹងពីតម្លៃមនុស្ស ការលើកដំកើងវប្បធម៌)

-វិស័យទី៣ ការអភិវឌ្ឍសង្គម និងអារម្មណ៍

-វិស័យទី៤ ការអភិវឌ្ឍការយល់ដឹងនិងការពិចារណា(ការអភិវឌ្ឍផ្នែកសិល្បៈច្នៃប្រឌិត)

-វិស័យទី៥ ការអភិវឌ្ឍផ្នែកភាសា (ការអភិវឌ្ឍផ្នែកភាសានិយាយ ការអភិវឌ្ឍផ្នែកការចេះអក្សរ ការអភិវឌ្ឍផ្នែកយល់ដឹងច្រើនភាសា ឬរៀនពីរភាសា)។

គ. កម្រងសំនួរសម្រាប់វាស់ស្ទង់ មានសំនួរគោលសម្រាប់គ្រូបង្រៀនសាលាបឋមសិក្សាផ្ទាល់ ដែលពាក់ពន្ធ័ពីស្ថានភាពទូទៅ និងអាត្រាចូលរៀន និងត្រួតថ្នាក់របស់សិស្សដោយទុករយះពេល១ថ្ងៃក្នុងការបំពេញ និងតេស្តវាស់សមត្ថភាព របស់សិស្ស ។ផលលំបាកមួយចំនួនក្នុងការចងក្រងឯកសារ មានតែក្នុងសៀវភៅ ពុំមានបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ពិបាកធ្វើការស្វែករក។

-ក្នុងការវាស់ស្ទង់លើកុមារតាមរយៈកម្រង់សំនួរ និងមានសម្ភារមួយចំនួន ត្រូវបានជ្រើសរើសនៅទីកន្លែងផ្ទាល់ ឯមួយចំនួនទៀតគឺមានស្រាប់ពីនាយកដ្ឋានអប់រំកុមារតូច ។មានការចូលរួមពីអ្នកគ្រូទទួលបន្ទុកថ្នាក់ក្នុងការជួយសម្របសម្រួលកិច្ចការនេះ ។តាមរយៈការធ្វើតេស្ត កុមារម្នាក់ចំណាយពេល

១៥ ទៅ២០នាទីជាមួយនិងការឆ្លើយតបក៏ដូចការធ្វើតេស្តតាមរយៈសម្ភារល្បែងដោយ មានជំនួយការម្នាក់ចាំគូសនូវចម្លើយនិងអង្កេតផ្ទាល់ ។ក្នុងរយៈពេល១ព្រឹកអាចធ្វើតេស្តជាមួយកុមារចំនួន៣ ទៅ៤នាក់ដោយសុំម៉ោងសិក្សារបស់គ្រូទទួលបន្ទុកថ្នាក់និមួយៗ និងមានការជួបសំណេះសំណាលផ្ទាល់ពីស្ថានភាពជាក់ស្តែងរបស់កុមារ ។

# ជំពូកទី៤

## ៤.១ របកគំហើញ

ជំពូកនេះនិយាយអំពីលទ្ធផលនៃការវិភាគទិន្នន័យដែលប្រមូលតាមរយៈការបញ្ចូលតាមកម្មវិធី Spss និងធ្វើការវិភាគតាម Chi-square ។

លទ្ធផលនៃការស្រាវជ្រាវត្រូវបានបែងចែកចេញជា៥ផ្នែកធំៗ :

១. អភិវឌ្ឍផ្នែកសិលធម៌ និងវប្បធម៌

២. អភិវឌ្ឍផ្នែកសិលធម៌ និងវប្បធម៌

៣. អភិវឌ្ឍផ្នែកភាសា

៤. អភិវឌ្ឍផ្នែកបញ្ញា និងការគិត

៥. អភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍

- ផ្នែកទី១ គឺជាលទ្ធផលនៃការវិភាគ ផ្នែកអភិវឌ្ឍផ្នែកសិលធម៌ និងវប្បធម៌ដូចដែលបានបង្ហាញក្នុងតារាង ៤.១។ នៅក្នុងតារាងទី១ មានអថេរ៥ ដើម្បីប្រៀបធៀបសមត្ថភាពកុមារបានចូលមត្តេយ្យ និងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យសិក្សា។

តារាង ៤.១.១ អភិវឌ្ឍផ្នែកសិលធម៌ និងវប្បធម៌

| អថេរ | ប្រភេទចំលើយ | បានរៀនមតេយ្យឬទេ | | *df* | $X^2$ |
|---|---|---|---|---|---|
| | | បាន<br>% | មិនបាន<br>% | | |
| ១ ជំរាបសួរ | បានល្អ | ១៩ (៧៩.២) | ៥(២០.៨) | ២ | ១៦.២៨<br>** |
| | បានខ្លះ | ១ (៩.១) | ១០ (៩០.៩) | | |
| | មិនបាន | 0 | ១(១០០) | | |
| ២ សំពះមនុស្សចាស់ | បានល្អ | ១៩ (៨២.២) | ៥ (២០.៨) | ២ | ១៩.0១<br>** |
| | បានខ្លះ | ១(១១.១) | ៨ (៨៨.៩) | | |
| | មិនបាន | 0 | ៤ (១០០) | | |
| ៣ ថ្វាយបង្គំលោកសង្ឃ | បានល្អ | ១៨ (៧៥.0) | ៦ (២៤.0) | ២ | ១១.២៩<br>** |
| | បានខ្លះ | ២ (២0.0) | ៨ (៨0.0) | | |
| | មិនបាន | 0 | ២(១០០) | | |
| ៤ រៀបរាប់បុណ្យសំខាន់ៗ | បានល្អ | ៧ (១០០) | 0 | ២ | ២៦.១២<br>** |
| | បានខ្លះ | ១៣ (៨១.៣) | ៣ (១៨.៨) | | |
| | មិនបាន | 0 | ១៣ (១០០) | | |

| | | | | | |
|---|---|---|---|---|---|
| ៥ ឧទាហរណ៍ខ្លឹមសារនៃបុណ្យ | បានល្អ | ៨(១០០) | 0 | ២ | ៣២.១៨ ** |
| | បានខ្លះ | ១១ (១០០) | 0 | | |
| | មិនបាន | ១ (៥.៩) | ១៦ (៩៤.២) | | |

- លទ្ធផលបានបង្ហាញឱ្យឃើញថា :

- ក្នុងអថេរទី១ ពេលយើងទៅដល់កុមារចេះជំរាបសួរ ឬទេ?

លទ្ធផលបង្ហាញថាកុមារដែលបានចូលរៀនសាលាមតេយ្យចេះជម្រាបសួរបានល្អក្នុងនោះកុមារដែលឆ្លងកាត់មត្តេយ្យមាន៧៩.២ភាគរយច្រើនជាងកុមារមិនបានរៀនសាលាមត្តេយ្យដែលមានចំនួនតែ ២០.៨ ភាគរយ តែប៉ុណ្ណោះ [$X^2$ ២, (n = ៣៦) = ១៦,២៨, p < .0១]

-ក្នុងអថេរទី២ ចូរកូនសំពះចាស់ៗនៅពេលភ្ញៀវមកដល់?

៨២.៦ភាគរយនៃសិស្សដែលបានចូលរៀនមត្តេយ្យមានភាពរហ័សរហួនជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ២០ភាគរយ ។ក្នុងការគោរពសំពះដល់មនុស្សចាស់អាចទុកថាជាការសាមញ្ញដែលកុមារទូទៅអាចធ្វើបានតាមរយៈការបង្ហាត់បង្ហាញរបស់អ្នកគ្រូមាតាបិតារឺអាណាព្យាបាលក្តីក៏ប៉ុន្តែក្នុងនោះកុមារក៏បង្កប់ភាពអៀនរឺការខ្លាចរអារចំពោះមនុស្សប្លែកមុខ ។ដោយឡែកកុមារដែលបានឆ្លងកាត់មត្តេយ្យមាន ភាពឱនលំទោននិងមានលក្ខណៈ ទន់ភ្លន់ជាងកុមារដែលមិនបានឆ្លង កាត់មត្តេយ្យ ។ [$X^2$ ២, (n = ៣៦) = ១៩,0១, p < .0១]

-អថេរទី៣ លើសំណួរថា "ពេលកូនទៅវត្តកូនថ្វាយបង្គំព្រះសង្ឃដូចម្តេច?"

៧៥ភាគរយនៃកុមារដែលបានឆ្លងកាត់មត្តេយ្យមានសមត្ថភាពអាចធ្វើបានល្អជាង ចំណែកឯកុមារដែលមិនបានឆ្លងកាត់មត្តេយ្យអាចធ្វើការបានតែ២៥%ប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតសកម្មភាពគួរឱ្យកត់សំគាល់គឺកុមារដែលឆ្លងកាត់មត្តេយ្យមានរបៀបតាំងពីការអង្គុយបត់ជើងលើកដៃទាំងពីរដាក់ត្រឹម ថ្ងាសហើយឱនសំពះបីលើកតែបើធៀបជាមួយកុមារដែលមិនបានឆ្លងកាត់មត្តេយ្យភាគច្រើនពួកគេគ្រាន់តែលើកដៃសំពះទូទៅដែលយើងពុំអាចចាត់ទុកថាពួកគេថ្វាយបង្គំលោកសង្ឃបានឡើយ ។ ករណីមួយវិញទៀតកុមារដែលមិនបានឆ្លងកាត់មត្តេយ្យធ្វើការថ្វាយបង្គំតាមរបៀប( សំពះចិន) នៅពេលដែលយើងសួរថាហេតុអ្វីបានជាធ្វើការសំពះបែបនេះកុមារឆ្លើយថាធ្លាប់តែឃើញឱពុក-ម្តាយគេសំពះសែនព្រេនរឺឆេងម៉េងតាំងពីដើមរៀងមក នេះបញ្ជាក់ឱ្យឃើញពីទំលាប់ជាប្រចាំធ្វើឱ្យកុមារឆាប់ទទួលយកជាង ទង្វើរឺសកម្មភាពដែលពុំសូវបានប្រព្រឹត្ត ។ [$X^2$ ២, (n = ៣៦) = ១១,២៩, p < .0១]

-អថេរទី៤ លើសំណួរថា ចូរកូនរៀបរាប់ពីបុណ្យសំខាន់ៗនៅក្នុងប្រទេសយើង?

១00ភាគរយនៃកុមារដែលបានចូលមត្តេយ្យរៀបរាប់បានក្បោះក្បាយជាងកុមារពុំបានឆ្លងមត្តេយ្យ ។ [$X^2$ ២, (n = ៣៦) = ២៦,១២, p < .0១]

-អថេរទី៥ ចូរកូនឱ្យឧទាហរណ៍ខ្លឹមសារនៃបុណ្យមួយដែលកូនបានចាំ?

១00ភាគរយកុមារដែលបានឆ្លងកាត់មត្តេយ្យរៀបរាប់បានល្អជាងបានជាយើងអាចសន្និដ្ឋានថាល្អ ព្រោះកុមារបានរៀបរាប់ជាហូរហែរដូចជាបុណ្យអុំទូក បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ បុណ្យឯករាជ្យ ជាដើម ។មិនតែប៉ុណ្ណោះពួកគេអាចរៀបរាប់ពីអត្ថន័យបានក្បះក្បាយជាងកុមារដែលមិនបានឆ្លងកាត់មត្តេយ្យ ដោយសារពួកគេបាន យល់ច្បាស់ពីខ្លឹមសាររបស់បុណ្យ ទាំងនោះ។ [$X^2$ ២, (n = ៣៦) = ៣២,១៨, p < .0១] ។

តារាង ៤.១.២ : អភិវឌ្ឍផ្នែកសុខភាព និងរាងកាយ :

| អថេរ | ប្រភេទចំលើយ | បានរៀនមតេយ្យឬទេ | | *df* | $X^2$ |
|---|---|---|---|---|---|
| | | បាន % | មិនបាន % | | |
| ១ របៀបដុះធ្មេញ សិតសក់ | បានល្អ | ១៩(៧0.៤) | ៨(២៩.៦) | ២ | ១៣.២ ** |
| | បានខ្លះ | 0 | ៨(១00) | | |
| | មិនបាន | ១(១00) | 0 | | |
| ២ ចេញពីបង្គន់ និងញ៉ាំបាយ | បានល្អ | ២0(៧៦.៩) | ៦(២៣.១) | ១ | ១៧.៣ |
| | បានខ្លះ | 0 | ១0(១00) | | |
| | មិនបាន | 0 | 0 | | |
| ៣ ដើរលើបន្ទះក្តារថយក្រោយ | បានល្អ | ២0(៦៦.៧) | ១0(៣៣.៣) | ១ | ៩.0 |
| | បានខ្លះ | 0 | ៦(១00) | | |
| | មិនបាន | 0 | 0 | | |
| ៤ រើសគ្រាប់ធញ្ញជាតិ | បានល្អ | ២0(៥៨.៨) | ១៤(៤១.២) | ១ | ២.៦៤ |
| | បានខ្លះ | 0 | ២(១00) | | |
| | មិនបាន | 0 | 0 | | |
| ៥ លោតអន្ទាក់ | បានល្អ | ១0(៨៣.៣) | ២(១៦.៧) | ២ | ៧.៧៣ * |
| | បានខ្លះ | ៥(៣១.៣) | ១១(៦៨.៨) | | |
| | មិនបាន | ៥(៦២.៥) | ១0(៥៥.៦) | | |
| ៦ ដោតបំពង់បឺត | បានល្អ | ១២(៦៦.៧) | ៦(៣៣.៣) | ១ | ១.៨ |

| | | | | | |
|---|---|---|---|---|---|
| | បានខ្លះ | ៨(៤៤.៤) | ១០(៥៥.៦) | | |
| | មិនបាន | 0 | 0 | | |

- លទ្ធផលបានបង្ហាញឱ្យឃើញថា :

- ក្នុងអថេរទី១ ចូរកូនប្រាប់ពីរបៀបដុសធ្មេញឱ្យអ្នកគ្រូមើល? សិតសក់?នៅពេលណាខ្លះ?

កុមារដែលបានចូលមត្តេយ្យចំនួន៧0.៤ភាគរយធ្វើបានល្អត្រឹមត្រូវដោយធ្វើការដុសធ្មេញពីលើចុះក្រោម៣ដងបន្ទាប់មក ពីស្តាំទៅឆ្វេងតាមលំដាប់លំដោយ មិនតែប៉ុណ្ណោះអាចសិតសក់បានយ៉ាងត្រឹមត្រូវស្អាតបាតព្រមទាំងអាចរៀបរាប់ពីពេលវេលាធ្វើអនាម័យខ្លួនបានយ៉ាងល្អ។ ២៩.៦%ប៉ុណ្ណោះសម្រាប់កុមារដែលមិនធ្លាប់ចូលមត្តេយ្យសិក្សា។ ប៉ុន្តែអ្វីដែលធ្វើឱ្យយើងកត់សំគាល់ទៅលើកុមារដែលមិនបានចូលមត្តេយ្យពិបាកធ្វើនោះ គឺពេលយើងចោទជាសំណួរថា តើធ្លាប់ធ្វើការដុសធ្មេញឬទេកុមារឆ្លើយថាធ្លាប់ ប៉ុន្តែនៅពេលយើងឱ្យធ្វើជាសកម្មភាពវិញម្តងកុមារហាក់មានភាពអៀនពុំសូវមានភាពក្លៀវក្លានិងត្រូវខ្លះ ខុសខ្លះ ក្នុងការបញ្ចេញសកម្មភាពប៉ុន្មាននោះទេបើទោះជាខំលើកទឹកចិត្តឱ្យពួកគេបញ្ចេញសកម្មភាព ក៏ដោយ។ [$X^2$ ២, (n = ៣៦) = ១៣,២, p < .0១]

-ក្នុងអថេរទី២ ពេលចេញពីបង្គន់និងមុនញ៉ាំបាយកូនធ្វើដូចម្តេច? (បានលាងដៃ មិនបានលាង)

កុមារដែលបានឆ្លងកាត់មត្តេយ្យធ្វើបានល្អចំនួន៧៦.៩ភាគរយរីឯកុមារដែលមិនបានចូលមត្តេយ្យអាចធ្វើបានត្រឹមតែ២៣.១ភាគរយ ។ព្រោះតាមតំបន់ឬមូលដ្ឋានរស់នៅរបស់កុមារមួយចំនួននៅប្រើទំលាប់បែប បុរាណ (បង្គន់ ជីកកប់)នៅឡើយ។ [$X^2$ ១, (n = ៣៦) = ១៧,៣0, p > .0៥]

-ក្នុងអថេរទី៣ ចូរកូនដើរលើបន្ទះក្តារថយក្រោយ

លទ្ធផលបង្ហាញថា៦៦.៧ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពបានរស់រវើកជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៣៣.៣ភាគរយ។ [$X^2$ ១, (n = ៣៦) = ៩,0, p > .0៥]

-ក្នុងអថេរទី៤ ចូរកូនរើសគ្រាប់ធញ្ញជាតិ(ពោត សណ្តែក ស្រូវ)ដាក់ក្នុងចាន

កុមារឆ្លងកាត់មត្តេយ្យអាចរើសបានល្អមាន៥៨.៨ភាគរយរីឯកុមារដែលមិនបានឆ្លងកាត់មត្តេយ្យ៤១.២ភាគរយ ។យើងអាចនិយាយថាវាសមត្ថភាពចលករតូច(ដៃ)រើសគ្រាប់ធញ្ញជាតិលាយឡំគ្នាមានដូចជាពោត សណ្តែក ស្រូវ ដាក់ក្នុងចានដែលឱ្យកុមារធ្វើការជ្រើសរើសនិងធ្វើចំណាត់ថ្នាក់នៃគ្រាប់ធញ្ញជាតិផ្សេងៗគ្នាចំពោះកុមារឆ្លងកាត់មត្តេយ្យមានសកម្មភាពរហ័សជាង។

[$X^2$ ១, (n = ៣៦) = ២,៦៤៧, p > .0៥] ។

-ក្នុងអថេរទី៥  ចូរកូនឡើងលោតអន្ទាក់ម្នាក់ឯងឱ្យអ្នកគ្រូមើល?

លទ្ធផលបង្ហាញថា៨៣.៣ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពបានរស់រវើកជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ១៦.៧ភាគរយ។ [$X^2$ ២, (n = ៣៦) = ៧,៧៣, p < .០៥]

-ក្នុងអថេរទី៦ ចូរកូនដោតបំពង់បឺតឆ្លាស់ពណ៌ឱ្យអ្នកគ្រូមើល?

លទ្ធផលបង្ហាញថា៦៦.៧ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពបានល្អនិងភាពប៉ិនប្រសប់នៃចលនាដៃជាង  កុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៣៣.៣ភាគរយ។ [$X^2$ ១, (n = ៣៦) = ១,៨០, p > .០៥]

តារាង៤.១.៣.អភិវឌ្ឍនផ្នែកភាសា

| អថេរ | ប្រភេទចំលើយ | បានរៀនមតេយ្យឬទេ | | df | $X^2$ |
|---|---|---|---|---|---|
| | | បាន % | មិនបាន % | | |
| ១ ស្តាប់សំឡេង | បានល្អ | ១៩(៥៩.៤) | ១៣(៤០.៦) | ១ | ១.៧ |
| | បានខ្លះ | ១(២៥) | ៣(៧៥) | | |
| | មិនបាន | ០ | ០ | | |
| ២ មុខងារច្រមុះ អណ្តាត ភ្នែក....... | បានល្អ | ៤(១០០) | ០ | ១ | ៣.៦ |
| | បានខ្លះ | ១៦(៥០) | ១៦(៥០) | | |
| | មិនបាន | ០ | ០ | | |
| ៣ ទៅផ្សារឃើញអ្វីខ្លះ | បានល្អ | ១៥(៨៨.២) | ២(១១.៨) | ២ | ១៤.០៤ ** |
| | បានខ្លះ | ៤(២៨.៦) | ១០(៧១.៤) | | |
| | មិនបាន | ១(២០) | ៤(៨០) | | |
| ៤ ម្តាយសួរធ្វើអ្វីខ្លះ | បានល្អ | ១៥(៩៣.៨) | ១(៦.៣) | ២ | ១៧.៩ ** |
| | បានខ្លះ | ៥(២៩.៤) | ១២(៧០.៦) | | |
| | មិនបាន | ០ | ៣(១០០) | | |
| ៥ សួរមិត្ត រួចប្រាប់អ្នកគ្រូ | បានល្អ | ២០(៧៤.១) | ៧(២៥.៩) | ២ | ១៥.០ ** |
| | បានខ្លះ | ០ | ៥(១០០) | | |
| | មិនបាន | ០ | ៤(១០០) | | |
| ៦ ឈ្មោះខែទាំង១២ | បានល្អ | ៧(១០០) | ០ | ២ | ១៩.៣៧ ** |
| | បានខ្លះ | ១៣(៦៨.៤) | ៦(៣១.៦) | | |

| | | | | | |
|---|---|---|---|---|---|
| | មិនបាន | 0 | ១០(១០០) | | |
| ៧ រករូបផ្ការលាក់ខ្លួនឱ្យគ្រប់ចំនួន | បានល្អ | ១៦(៧២.៧) | ៦(៣៧.៥) | ១ | ៦.៧៥ |
| | បានខ្លះ | ៤(២៨.៦) | ១០(៧១.៤) | | |
| | មិនបាន | 0 | 0 | | |
| ៨ ចម្លងរូបរាង | បានល្អ | ១៧(៦០.៧) | ១១(៣៩.៣) | ១ | ១.៣៥ |
| | បានខ្លះ | ៣(៣៧.៥) | ៥(៦២.៥) | | |
| | មិនបាន | 0 | 0 | | |

- លទ្ធផលបានបង្ហាញឱ្យឃើញថា :

-អថេរទី១ ចូរកូនផ្ទៀងស្ដាប់ មើល តើជាសំឡេងអ្វី?

លទ្ធផលបង្ហាញកុមារដែលឆ្លងកាត់មត្តេយ្យ៥៩.៤ភាគរយអាចផ្ទៀងស្ដាប់បានល្អជាងកុមារដែលមិនបានឆ្លងកាត់មត្តេយ្យ៤០.៦ភាគរយ ។ចំពោះឧបករណ៍និងសកម្មភាពទី១គ្រូបង្ហាញពីឧបករណ៍មានដូចជាកំប៉ុងគ្រាប់គ្រួសគំរប់ដបទឹកគ្រួចនិងគ្រាប់ឡុកឡាក់ហើយចាប់ផ្ដើមក្រឡុកម្ដង១ៗ ឱ្យកុមារស្ដាប់បន្ទាប់មកទៀតក្រឡុកបញ្ចូលគ្នាឱ្យកុមារផ្ទៀងផ្ទាត់ស្ដាប់មើល ចំពោះសមត្ថភាពស្ដាប់ប្រហាក់ប្រហែលគ្នាគ្រាន់តែកុមារឆ្លងមត្តេយ្យឆាប់ចាប់បានព្រមទាំងរៀបរាប់បានល្អជាង ។

[$X^2$ ១, (n = ៣៦) = ១,៧០២, p > .០៥]

-អថេរទី២ ចូរកូនរៀបរាប់ពីមុខងាររបស់ច្រមុះ អណ្ដាត ត្រចៀក ភ្នែក ស្បែក ?

លទ្ធផលបង្ហាញ១០០ភាគរយនៃកុមារចូលមត្តេយ្យអាចរៀបរាប់ពីមុខងារច្រមុះ(ឃានវិញ្ញាណ) អណ្ដាត(ជីវ្ហាវិញ្ញាណ) ត្រចៀក(សោតវិញ្ញាណ) ភ្នែក(ចក្ខុវិញ្ញាណ) និងស្បែក(កាយវិញ្ញាណ) ជាងកុមារពុំឆ្លងមត្តេយ្យ0ភាគរយ ។ប៉ុន្តែបើធ្វើការប្រៀបធៀបទៅលើសកម្មភាព"ធ្វើបានខ្លះ៧"កុមារទាំងពីរក្រុមមានភាគរយប្រ ហាក់ប្រហែលគ្នា ។

[$X^2$ ១, (n = ៣៦) = ៣,៦០, p > .០៥]

-អថេរទី៣ ពេលកូនទៅផ្សារកូនបានឃើញអ្វីខ្លះ?

លទ្ធផលបង្ហាញថា៨៨.២ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យរៀបរាប់បានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ១១.៨ភាគរយ ។ [$X^2$ ២, (n = ៣៦) = ១៤,០៤២, p < .០១]

-អថេរទី៤ តើកូនមានដែលឃើញម្ដាយកូនស្លរទេ? តើគាត់ធ្វើដូចម្ដេចដើម្បីស្ល?

លទ្ធផលបង្ហាញថា៩៣.៨ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យអាចយល់ព្រមរៀបរាប់តាមលំដាប់លំដោយជាង កុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៦.៣ភាគរយ ។

[$X^2$ ២, (n = ៣៦) = ១៧,៩០, p < .០១]

-អថេរទី៥ ចូរកូនសួរទៅមិត្តថាតើគេចូលចិត្តញ៉ាំអ្វី?រួចប្រាប់អ្នកគ្រូផង

លទ្ធផលបង្ហាញថា៧៤.១ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យចេះធ្វើទំនាក់ទំនងនិងចេះសន្ទនាបានរស់រវើកជាង កុមារដែលពុំបានឆ្លងកាត់មត្តេយ្យ២៥.៩ភាគរយ។ [$X^2$ ២, (n = ៣៦) = ១៥,00, p < .0១]

-អថេរទី៦ ចូរកូនប្រាប់ឈ្មោះខែទាំង១២ក្នុង១ឆ្នាំ?

លទ្ធផលបង្ហាញថា១00ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពរៀបរាប់បានយ៉ាងក្បោះក្បាយជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ0ភាគរយ ។កម្មវិធីសិក្សាមត្តេយ្យរដ្ឋមុខវិជ្ជា ទម្លាប់ល្អ (កាលបរិច្ឆេទ) តម្រូវឱ្យកុមារធ្វើការសន្ទនាពីចំនួនថ្ងៃ ខែ ឆ្នាំ ជារៀងរាល់ថ្ងៃជាទម្លាប់កុមារងាយស្រួលចងចាំជាង។ [$X^2$ ២, (n = ៣៦) = ១៩,៣៧, p < .0១]

-អថេរទី៧ ចូរកូនរករូបឆ្នាដែលលាក់ខ្លួនឱ្យបានចំនួនប្រាំពីរ?

លទ្ធផលបង្ហាញថា៧២.៧ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើបានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៣១.៦ភាគរយ ។កុមារដែលបានឆ្លងកាត់មត្តេយ្យមានលទ្ធភាពស្វែងយល់រហ័សរហួន និងចេះរៀបរាប់អំពីទីតាំងបំលាស់ទីរបស់សត្វឆ្មានីមួយៗ។ [$X^2$ ១, (n = ៣៦) = ៦,៧៥, p > .0៥]

-អថេរទី៨ ចូរកូនចំលងរូបរាង

លទ្ធផលបង្ហាញថា៦0.៧ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពបានរស់រវើកជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៣៩.៣ភាគរយ។ [$X^2$ ១, (n = ៣៦) = ១,៣៥, p >.0៥]

តារាង ៤.១.៤ : អភិវឌ្ឍផ្នែកបញ្ហា និងការគិត

| អថេរ | ប្រភេទចំលើយ | បានរៀនមតេយ្យឬទេ | | *df* | $X^2$ |
|---|---|---|---|---|---|
| | | បាន % | មិនបាន % | | |
| ១ប្រាប់ឈ្មោះរូបរាងចតុកោណ | បានល្អ | ៩(១00) | 0 | ២ | ២៤.១២ ** |
| | បានខ្លះ | ១១(៧៣.៣) | ៤(២៦.៧) | | |
| | មិនបាន | 0 | ១២(១00) | | |
| ២ រូបរាងស្លាបព្រា | បានល្អ | ១១(១00) | 0 | ២ | ៣២.១៨ ** |
| | បានខ្លះ | ៨(១00) | 0 | | |
| | មិនបាន | ១(៥.៩) | ១៦(៩៤.១) | | |
| ៣ ប្រៀបធៀបរង្វាស់. | បានល្អ | ២0(៥៥.៦) | ១៦(៤៤.៤) | N. | n.a |

| | | | | | |
|---|---|---|---|---|---|
| ប្រវែង..... | បានខ្លះ | 0 | 0 | a | |
| | មិនបាន | 0 | 0 | | |
| ៤ ប្រៀបធៀបចំនួនតិច ច្រើន | បានល្អ | ១៥(៥១.៧) | ១៤(៤៨.៣) | ២ | ៣.២៥* |
| | បានខ្លះ | ៥(៨៣.៣) | ១(១៦.៧) | | |
| | មិនបាន | 0 | ១(១00) | | |
| ៥ រៀបវត្ថុតាមលំដាប់លំដោយ | បានល្អ | ១៧(៥៤.៨) | ១៤(៤៥.២) | ១ | .0៤៦ |
| | បានខ្លះ | ៣(៦0) | ២(៤00) | | |
| | មិនបាន | 0 | 0 | | |

- លទ្ធផលបានបង្ហាញឱ្យឃើញថា :

-អថេរទី១ ចូរកូនប្រាប់ឈ្មោះរាងទាំងនេះ? )រង្វង់ +ត្រីកោណ ›ការេ  ចតុកោណ

លទ្ធផលបង្ហាញថា១00ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើបានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ។ [$X^2$ ២, (n = ៣៦) = ២៤,១២, p < .0១]

-អថេរទី២ ស្លាបព្រា(ស្លឹកឈើ ផ្លែស្វាយ.......) មានរូបរាងដូម្តេច?

លទ្ធផលបង្ហាញថា១00ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើបានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ។ [$X^2$ ២, (n = ៣៦) = ៣២,១៨, p < .0១]

-អថេរទី៣ ចូរកូនប្រៀបធៀបរង្វាស់ ប្រវែង វែង ខ្លី វែងជាង វែងបំផុត ខ្លីបំផុត

លទ្ធផលបង្ហាញថាកុមារឆ្លងកាត់មត្តេយ្យនិងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យធ្វើបានដូចគ្នា។ ដោយសារក្នុងជិវភាពប្រចាំថ្ងៃកុមារីក្នុងរង្វង់គ្រួសារកុមារអនុវត្តជាក់ស្តែងកុមារមានបំណិនប្រសប់លើសមត្ថភាពសមហេតុផល។ ស្របតាមអាយុកាលនៃការវិវត្តន៏របស់កុមារ កុមារម្នាក់ៗមានសមត្ថភាពមានស្រាប់ផ្សេងៗគ្នាតាមបែបបទរស់នៅគ្រាន់តែកុមារនៅមានភាពភ័នច្រលំខ្លះៗ ដូច្នោះមត្តេយ្យសិក្សាអាចជួយបំពេញបន្ថែមនិងដុសខាត់លើសមត្ថភាពកុមារឱ្យកាន់ប្រសើរឡើងថែមទៀត។

-អថេរទី៤ ចូរធ្វើការប្រៀបធៀបចំនួនតិចជាង ច្រើនជាង(រង្វាស់ទឹកក្នុងកែវ និងចានទាប)?

លទ្ធផលបង្ហាញថា៥១.៧ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើបានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៤៨.៣ភាគរយ។

[$X^2$ ២, (n = ៣៦) = ៣,៩២, p < .0៥]

-អថេរទី៥ ចូរកូនរៀបចំវត្ថុតាមលំដាប់ពីតូចទៅធំ?(ស្លឹកឈើ ផ្កា......)

លទ្ធផលបង្ហាញថា ៥៤ភាគរយនៃកុមារឆ្លងកាត់មត្តេយ្យធ្វើបានល្អជាងកុមារដែលពុំបានឆ្លងកាត់មត្តេយ្យ៤៥។ [$X^2$ ១, (n = ៣៦) = .0៤៦, p > .0៥]

តារាង ៤.១.៥ : អភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍

| អថេរ | ប្រភេទចំលើយ | បានរៀនមតេយ្យឬទេ | | *df* | $X^2$ |
|---|---|---|---|---|---|
| | | បាន % | មិនបាន % | | |
| ១ ផ្គុំរូបរាងមនុស្ស | បានល្អ | ៤(១00) | 0 | ២ | ៥.៩៥ * |
| | បានខ្លះ | ៧(៧0) | ៣(៣0) | | |
| | មិនបាន | ៩(៤0.៩) | ១៣(៥៩.១) | | |
| ២ ដើរតួ ជាឳពុក-ម្តាយ | បានល្អ | ៤(១00) | 0 | ២ | ៧.៥១ * |
| | បានខ្លះ | ៧(៧៧.៨) | ២(២២.២) | | |
| | មិនបាន | ៩(៣៩.១) | ១៤(៦0.៩) | | |
| ៣ គូររូប | បានល្អ | ១៧(៧0.៨) | ៧(២៩.២) | ២ | ៧.0៨ * |
| | បានខ្លះ | ៣(២៧.៣) | ៨(៧២.៧) | | |
| | មិនបាន | 0 | ១(១00) | | |
| ៤ រៀបរាប់មនុស្សដែលចូលចិត្ត | បានល្អ | ២0(៥៥.៦) | ១៦(៤៤.៤) | n.a | n.a |
| | បានខ្លះ | 0 | 0 | | |
| | មិនបាន | 0 | 0 | | |
| ៥ រៀបរាប់ល្បែងដែលចូលចិត្ត លេង | បានល្អ | ២0(៥៧.១) | ១៥(៤២.៩) | ១ | ១.២៨ |
| | បានខ្លះ | 0 | ១(១00) | | |
| | មិនបាន | 0 | 0 | | |

- លទ្ធផលបានបង្ហាញឱ្យឃើញថា :

-អថេរទី១ចូរកូនផ្គុំរូបមនុស្ស?

១00ភាគរយនៃកុមារបានចូលមត្តេយ្យអាចផ្គុំរូបមនុស្សបានល្អជាងកុមារពុំឆ្លងកាត់មត្តេយ្យដែលពុំអាចធ្វើល្អបាន ។ល្បែងផ្គុំរូបមនុស្ស ស្ថិតនៅក្នុងសកម្មភាពកសាង កុមារដែលឆ្លងកាត់មត្តេយ្យធ្វើសកម្មភាពបានរហ័សជាង ប៉ុន្តែក៏មិនមានន័យថា កុមារពុំឆ្លងកាត់មត្តេយ្យអត់មានសមត្ថភាពក្នុងកសាងនោះដែរ គ្រាន់តែកុមារនៅមានការភាន់ច្រលំលើសកម្មភាពមួយចំនួនតែប៉ុណ្ណោះ ។

[$X^2$ ២, (n = ៣៦) =៥.៩៥, p < .0៥]

-អថេរទី២ ចូរកូនដើរតួធ្វើជាឪពុកម្តាយ ដោយប្រើរូបតុក្កតា?

ស្ថិតក្នុងសកម្មភាពល្បែងត្រាប់តាម កុមារដែលឆ្លងកាត់មត្តេយ្យ១០០ភាគរយអាច ធ្វើបានល្អជាង ដែលពុំសូវមានភាពអៀនខ្មាស់ ដូចកុមារពុំបានឆ្លងកាត់មត្តេយ្យ ។

[$X^2$ ២, (n = ៣៦) = ៧.៥១, p < .០៥]

-អថេរទី៣ ចូរកូនគូររូបមួយដែលកូនពេញចិត្ត?

៧០.៨ភាគរយនៃកុមារចូលមត្តេយ្យធ្វើបានល្អជាងក្នុងនោះកុមារពុំចូលមត្តេយ្យ២៩.២ភាគរយ ។ អ្វីដែលជាភាពខុសប្លែកគ្នាខ្លាំង កុមារមានបំនិនចលករតូច ដែលបង្ហាញឱ្យឃើញពីកំលាំង និងការសម្របសម្រួលនៃសាច់ដុំតូចៗគឺរបៀបកាន់ខ្មៅដៃកុមារមត្តេយ្យចាប់កាន់ទំនងជាង មានម្ចាស់ការបញ្ជាលើចលនាខ្មៅដៃបានយ៉ាងស្ទាត់ ជាងកុមារដែលពុំឆ្លងកាត់មត្តេយ្យ ។

[$X^2$ ២, (n = ៣៦) = ៧.០៨, p < .០៥]

-អថេរទី៤ តើកូនចូលចិត្តអ្នកណាជាងគេនៅក្នុងគ្រួសារកូន?

៥៥.៦ភាគរយនៃកុមារចូលមត្តេយ្យឆ្លើយបានល្អ ជាងកុមារដែលពុំឆ្លងកាត់មត្តេយ្យ៤៤.៤ភាគរយ ។

-អថេរទី៥ តើកូនចូលចិត្តលេងល្បែងអ្វីជាងគេ?( បាល់ទាត់ លេងមីក លោតអន្ទាក់...)

៥៧.១ភាគរយនៃកុមារចូលមត្តេយ្យឆ្លើយបានល្អ ជាងកុមារដែលពុំឆ្លងកាត់មត្តេយ្យ៤២.៩ភាគរយ ។

[$X^2$ ១, (n = ៣៦) = ១.២៨, p > .០៥]

## ៤.២ លទ្ធផល និងការពិភាក្សា

តាមការធ្វើការអង្កេតលើកុមារចំនួន៣៦នាក់ ដែលមកពីសាលាបឋមសិក្សាពីរ ហើយក្នុងចំណោមសិស្ស៣៦នាក់ ១៦នាក់ដែលពុំបានឆ្លងកាត់មត្តេយ្យសិក្សា ទាំងផ្នែកមត្តេយ្យរដ្ឋមត្តេយ្យ សហគមន៍ក៏ដូចជាមត្តេយ្យតាមខ្នងផ្ទះ( ម៉ែៗស្ម័គ្រចិត្តបង្រៀន) ។ វិញ្ញាសាដែលបានយកមកធ្វើតេស្តត្រូវបានដកស្រង់យកពីឯកសារស្តង់ដាររបស់នាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំយុវជន និងកីឡា ។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថាក្នុងគ្រប់ករណីកុមារដែលបានឆ្លងកាត់មត្តេយ្យតែងតែ ឆ្លើយតបបានល្អប្រសើរជាងកុមារដែលមិនមានសាវតាឆ្លងកាត់មត្តេយ្យដោយពួកគេមានភាពក្លាហានស៊ាំ និងបរិយាកាសសាលារៀន ។ លទ្ធផលនៃការសិក្សានេះក៏បានបង្ហាញនៅក្នុងការស្រាវជ្រាវមួយ របស់អង្គការ Unicef(Nirmala Rao and Emma Pesrson) ដោយផ្តោតលើការធ្វើតេស្តវាស់ស្ទង់សមត្ថភាពកុមារមត្តេយ្យនិងកុមារពុំបានឆ្លងកាត់មត្តេយ្យលើ៦ខេត្ត-ក្រុង ។ តេស្តត្រូវបានធ្វើពីរដំណាក់កាលរវាងកុមារពីរក្រុម ទី១មុនចូលបឋមសិក្សា (pre-test) ទី២ និងនៅពេលដែលពួកគេចាប់រៀនថ្នាក់ទី១ (post-test) ។បានបង្ហាញថាគ្រប់សិស្សដែលបានចូលរៀនមត្តេយ្យទាំងបីក្រុម មត្តេយ្យរដ្ឋ សហគមន៍ អប់តាមខ្នងផ្ទះ អនុវត្តបានល្អជាងក្រុមមិនបានចូលរៀនថ្នាក់មត្តេយ្យទាំងមុន និងក្រោយពេលចូល

រៀនថ្នាក់ទី១ ។ហើយមិនមានការខុសប្លែកគ្នារវាងក្រុមមត្តេយ្យ សហគមន៍ និងមត្តេយ្យតាមខ្នងផ្ទះដែរ ក្រុមមត្តេយ្យរដ្ឋធ្វើតេស្តបានពិន្ទុច្រើនជាងក្រុមក្រុមមត្តេយ្យសហគមន៍ និងមត្តេយ្យតាមខ្នងផ្ទះនៃបណ្តាជំនាញភាសាជំនាញចំណេះដឹងទូទៅនិងជំនាញចលកម្ម ។ ហើយអ្វីដែលបានបង្ហាញលើលទ្ធផលឃើញថាសម្រាប់ជំនាញចលកម្ម(ចលករ)ក៏មិនមានការខុសប្លែកគ្នាទេ រវាងក្រុមកុមារដែលចូលសាលាមត្តេយ្យ និងក្រុមមិនបានចូលរៀនដោយសារសកម្មភាពប្រចាំថ្ងៃរបស់ពួកគេដូចជា:ការរត់ លោត ឡើង លូន... សកម្មភាពទាំងនេះ កុមារក្រៅសាលាមានសេរីភាពជាង ។ ប៉ុន្តែនៅក្នុងកម្មវិធីមត្តេយ្យពុំផ្តោតឱ្យកុមារអភិវឌ្ឍតែមួយផ្នែកទេ កុមារលូតលាស់តាមអាយុ គ្រប់ផ្នែករបស់កុមារត្រូវបានដុសខាត់យ៉ាងល្អ ប្រសិនបើកុមារទទួលបានការអប់រំមួយទាន់ពេលវេលា ។

នៅក្នុងការសិក្សាក្នុងមត្តេយ្យរដ្ឋ គឺផ្តោតសំខាន់ទៅលើបុរេគណិត ដែលលាយឡំនឹងលក្ខណៈវិទ្យាសាស្ត្រ បុរេភាសា ហើយនៅក្នុងនោះដែលត្រូវបានបែងចែកជា៥ផ្នែកនៃការអភិវឌ្ឍតាមចិត្តវិទ្យារបស់កុមារ ។ សម្ភារៈជាផ្នែកមួយជួយអភិវឌ្ឍដល់កុមារលើមុខវិជ្ជាទាំងឡាយប៉ុន្តែយើងនៅមានការខ្វះខាតនូវធនធានសម្ភារៈដែលសមស្របទាន់សម័យកាលទៅតាមលក្ខណៈវិទ្យាសាស្ត្រ ដូចសាលាមត្តេយ្យឯកជននានាក្នុងទីក្រុងនោះឡើយ ។ ទោះជាយ៉ាងណាក៏ដោយសម្ភារៈឧបទ្ទេសនៅតាមតំបន់ផ្សេងៗ ត្រូវបានផលិតឡើងដោយសារការកែច្នៃនូវវត្ថុធាតុដើមក្នុងតំបន់ដែលមានស្រាប់ មិនមានលក្ខណៈបទដ្ឋានជាសកលឱ្យសិស្សគ្រប់គ្នាយល់ទាំងអស់នោះទេ ។ ទោះជាយ៉ាងណាក៏កុមារដែលទទួលបានការអប់រំនៅមត្តេយ្យនៅតែមានលទ្ធផលជាទីគាប់ប្រសើរជាងកុមារដែលពុំបានទទួលការអប់រំដែរ ហើយទស្សនៈដែលយល់ឃើញថាការអប់រំនៅមត្តេយ្យគ្រាន់តែជាការលេងសប្បាយតែមួយមុខប៉ុណ្ណោះ ។ប៉ុន្តែយើងកុំភ្លេចកុមារចូលចិត្តលេង ការលេងរបស់កុមារគឺរៀន ។

### ~ ទស្សនៈមតិរបស់លោកគ្រូ-អ្នកគ្រូ

មតិនិងទស្សនៈរបស់លោកគ្រូ-អ្នកគ្រូទៅលើ "កូនសិស្ស" ត្រូវបានធ្វើឡើងដើម្បីផ្តល់បន្ថែមនូវឥស្សុតាង ទៅលើ ភាពសមហេតុផលទៅលើលទ្ធផលដែលទទួលបាន ។ ដោយប្រើប្រាស់នូវសំណួរបើកគ្រូទាំងអស់ត្រូវបានស្នើរឱ្យចង្អុលបង្ហាញអំពីទស្សនៈរបស់គេ ថាតើវាមានសារៈសំខាន់សំរាប់កុមារក្នុងការចូលសិក្សាមត្តេយ្យមុនពេលចូលរៀនថ្នាក់ទី១រឺអត់ ។ ទស្សនៈរបស់ពួកគេក៏ត្រូវបានគេស្វែងរកដើម្បីធ្វើការអង្កេតទៅលើការសិក្សារបស់សិស្សនិងកែសម្រួលនូវភាពខុសប្លែកគ្នារវាងសិស្សដែលមានសាវតាមត្តេយ្យនិងសិស្សដែលមិនមាន ។គ្រប់ចម្លើយរបស់គ្រូទាំងអស់បានឯកភាពថា វាមានសារៈសំខាន់ណាស់ដែលកុមារត្រូវឆ្លងកាត់មត្តេយ្យសិក្សា ។មតិយោបល់របស់គ្រូៗទៅលើការសិក្សាក្នុងថ្នាក់ទី១ដោយផ្អែកទៅលើការអង្កេតនិងបទ ពិសោធន៍របស់ពួកគាត់ បានគាំទ្រនូវរបកគំហើញនៃការសិក្សាស្រាវជ្រាវដែលថាកុមារដែលបានឆ្លងកាត់មត្តេយ្យ សិក្សាមានទំនោររៀនពូកែជាងមិត្តភក្ត្ររបស់ពួកគេដែលមិនបានឆ្លង

កាត់មត្តេយ្យ។ លោកគ្រូ-អ្នកគ្រូទាំងបាន ធ្វើការអះអាងថាកុមារដែលបានឆ្លងកាត់មត្តេយ្យសិក្សា មានលក្ខណៈត្រៀមខ្លួនរួចរាល់សម្រាប់ថ្នាក់បឋមសិក្សាដោយសារពួកគេទទួលបាននូវជំនាញខ្លះៗរួមមក ហើយកាលពេលដែលពួកគេរៀនមត្តេយ្យដូចជា ជំនាញអាន ជំនាញសរសេរជាដើម។ ពួកគេសំដែង យោបល់ថាការទទួលបាននូវជំនាញខ្លះៗទាំងនោះហើយដែលធ្វើឱ្យក្រុមមត្តេយ្យមានភាពនាំមុខក្នុងផ្នែក ទំនាក់ទំនង ការរាប់ ការចាប់កាន់បិចរីខ្មៅដៃ ដែលរួមបញ្ចូលទាំង ការសរសេរ និងគំនូរផងដែរ។

យោងទៅលើបទពិសោធមួយចំនួនរបស់លោកគ្រូ-អ្នកគ្រូដូចខាងក្រោម:

ក-សិស្សបានបញ្ចប់ថ្នាក់មត្តេយ្យ:

ចេះពីការឆ្លើយរបស់គ្រូគេអាចធ្វើការកត់សំគាល់បានថាដែលបានចូលមត្តេយ្យមានលទ្ធភាពធ្វើ ការទំនាកទំនងដោយសេរីជាមួយគ្រូបង្រៀននិងមិត្តរួមថ្នាក់របស់ពួកគេ ។ដែលទាំងនេះពួគគេចេះតាំងពី មត្តេយ្យ និងជំនាញឯទៀតដូចជាការអានដែលអាចធ្វើឱ្យពួកគេអនុវត្តកិច្ចការពាក់ព័ន្ធផ្សេងៗបាន លឿន។ មិនថែមតែប៉ុណ្ណោះ ពួកគេអាចចាប់កាន់ ខ្មៅដៃបាន យ៉ាងល្អទៀតផង។

ខ-សិស្សដែលមិនបានបញ្ចប់ថ្នាក់មត្តេយ្យ:

តាមការប្រមែប្រមូលពីការឆ្លើយរបស់គ្រូទាំងឡាយបានឱ្យយើងដឹងថាពួកកុមារដែលមិនបានរៀនមត្តេយ្យមានភាពអៀនខ្មាស់ច្រើនមានភាពភ័យខ្លាចក្នុងការនិយាយទៅកាន់គ្រូបង្រៀននិងមិត្តរួមថ្នាក់របស់គេ ។ពួកគេមិនអាចចាប់កាន់ខ្មៅដៃបានដោយត្រឹមត្រូវនោះទេហើយថែមទាំងខ្មាស់អៀនក្នុងការធ្វើទំនាក់ទំនងដោយសេរីទៀតផង។

## ៤.៣ មូលហេតុដែលសិស្សមិនបានឆ្លងកាត់មត្តេយ្យ

ក្រោមកិច្ចសហការណ៏របស់អង្គការក្រៅរដ្ឋាភិបាលក្នុងការជួយបង្កើតមត្តេយ្យសហគមន៏ទៅតាមតំបន់ដាច់ស្រយាលដើម្បីប្រមូលកុមារឱ្យបានចូលរៀនថ្នាក់មត្តេយ្យនិងឈានបន្តទៅដល់ថ្នាក់បឋមសិក្សាដោយពុំមានការបោះបង់អត្រាត្រួតថ្នាក់ខ្ពស់គួរឱ្យកត់សំគាល់ក៏ដោយ ។ស្ថិតនៅក្រោមការសង្កេតទៅលើមូលហេតុកុមារពុំបានឆ្លងកាត់មត្តេយ្យ:

-កត្តាភូមិសាស្ត្រ:តាមបណ្តាភូមិដែលមានដង់ស៊ីតេប្រជាជនទាបនោះការបង្កើត មត្តេយ្យមិនត្រូវបានផ្តល់ ជា អាទិភាពប៉ុន្មាននោះទេ បើទោះជាមានការស្នើសុំពីសំណាក់អាជ្ញាធរភូមិក៏ដោយ។

- ការអប់រំមាតា:វាមានទំនាក់ទំនងយ៉ាងពិសេសរវាងកំរិតអប់រំរបស់មាតា និងប្រភេទនៃកម្មវិធីដែលកុមារត្រូវចូលសិក្សា ។តាមការសិក្សាស្រាវជ្រាវមាតានៃក្រុមកុមារដែលមិនបានចូលសិក្សាមត្តេយ្យមួយចំនួនមានកំរិតអប់រំទាបជាងមាតានៃក្រុមកុមារដែលបានទទួលការអប់រំមត្តេយ្យ។

-កត្តាជីវភាព:ឪពុក-ម្តាយកុមារមានជីវភាពមិនធូរធារដែលជាហេតុបណ្តាលឱ្យពួកគាត់គិតថាការចូលរៀនថ្នាក់មត្តេយ្យ ជាការឥតប្រយោជន៏ខាងបង់ពេលវេលានិងប្រាក់កាស់ដ៏ខ្សត់ខ្សោយរបស់ពួក

គាត់។ ឧទាហរណ៍ក្នុងករណីសិក្សារបស់យើងចំងាយពីភូមិស្អាងទៅភូមិស្មោយ៉ៃដែលមានមត្តេយ្យសិក្សា នោះគេត្រូវចំណាយពេលធ្វើដំណើរលើកំណាតផ្លូវប្រវែង ១គ.ម ដែលជាហេតុបណ្តាលឱ្យខាត់ពេលវេលារកស៊ីចិញ្ចឹមជីវិតរបស់ឪពុក-ម្តាយទាំងនោះដែលត្រូវជូន កូនទៅសិក្សា។

-កត្តាធនធានៈ ថវិការក្នុងការបង្កើតមត្តេយ្យសហគមន៍ដោយពុំមានការជួយឧបត្ថម្ភពីអង្គការនានា ខ្វះខាតគ្រូមត្តេយ្យដែលត្រូវធ្វើការនៅក្នុងភូមិសាស្រ្តដាច់ស្រយាជាទូទៅគ្រូមត្តេយ្យច្រើនជានារីភេទ។

# ជំពូកទី៥
# ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ ការសន្និដ្ឋាន

ផ្អែកទៅតាមការស្រាវជ្រាវខាងលើយើងឃើញថាកុមារត្រូវមានភាពចំបាច់ក្នុងការចូលរៀនមត្តេយ្យក៏ពិតមែនប៉ុន្តែក្នុងនោះឪពុក-ម្តាយដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលជួយកូន របស់គាត់ក្នុងវ័យដំបូង។

ការពាក់ព័ន្ធរបស់ឪពុក-ម្តាយពិតជាមានឥទ្ធិពលទៅលើការអភិវឌ្ឍផ្នែកបញ្ញា និងសង្គមរបស់កុមារ។តាមការស្រាវជ្រាវសិក្សាទៅលើការតភ្ជាប់រវាងការពាក់ព័ន្ធរបស់អាណាព្យាបាលធៀប ទៅនឹងលទ្ធផលនិងកម្មវិធីដែលគេបានវាយតំលៃដើម្បីបង្ហាញពីដំណើរការរបស់វា។ ដំណើរការនៃការ ពាក់ព័ន្ធរបស់ឪពុក-ម្តាយចំពោះការអប់រំកុមារតូចការស្រាវជ្រាវដ៏ត្រឹមត្រូវគាំទ្រលើការពាក់ព័ន្ធរបស់ឪពុក-ម្តាយបង្ហាញថាការពាក់ព័ន្ធរបស់ឪពុក-ម្តាយអាចត្រូវបានធ្វើឱ្យប្រសើរឡើងៗជាមួយនឹងលទ្ធផលជាវិជ្ជមានសំរាប់កុមារតូចនិងភាពរួចរាល់របស់ពួកគេក្នុងការចូលសិក្សា។ ដើម្បីសំរេចបានលទ្ធផលទាំងនេះវាមានសារៈសំខាន់ណាស់ ក្នុងការផ្សាភ្ជាប់រវាងតំរូវការអភិវឌ្ឍរបស់កុមារអត្តចរិត និងការប្រព្រឹត្តរបស់ឪពុក-ម្តាយការពាក់ព័ន្ធនៃការរំពឹងទុកនិងការគាំទ្រនៃកម្មវិធីអប់រំកុមារតូច។ផ្អែកទៅលើឥស្តុតាងជាក់ស្តែងបង្ហាញថា មានការពាក់ព័ន្ធបីសំខាន់ៗ ទៅលើលទ្ធផលដែលយើងទទួលបានគឺៈការចិញ្ចឹមបីបាច់ពីសំណាក់ឪពុក-ម្តាយទំនាក់ទំនងរវាងផ្ទះ និងសាលា និងការទទួលខុសត្រូវនៃលទ្ធផលនៃការសិក្សា។ ការចិញ្ចឹមបីបាច់ពីសំណាក់ឪពុក-ម្តាយសំដៅទៅលើឥរិយាបទតម្លៃ និងការការចិញ្ចឹមបីបាច់កុមារតូចទាំងនោះ។ទំនាក់ទំនងរវាងផ្ទះ និងសាលាគឺជាទំនាក់ទំនងផ្លូវការនិងមិនផ្លូវការរវាងគ្រួសារនិង អង្គភាពការទទួលខុសត្រូវនៃលទ្ធផលនៃការសិក្សាគឺជាទិដ្ឋភាពមួយដែលឪពុកម្តាយដាក់ការសង្កត់ធ្ងន់ទៅលើបណ្តាសកម្មភាពតាមផ្ទះនិងសហគមន៍ដែលជួយជំរុញជំនាញសិក្សារបស់ក្មេងៗទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយក្នុងការសិក្សានេះមិនបានយកគ្រប់សកម្មភាពទាំងអស់ខាងលើនោះទេ។

បញ្ហាការទាក់ទិននានារបស់ឪពុក-ម្តាយក្នុងការអភិវឌ្ឍន៍កុមារតូច កុមារតូចទាំងឡាយនិងបានទទួលផលប្រយោជន៍យ៉ាងច្រើនពីបណ្តាឆ្នាំដំបូងនៃសាលា ប្រសិនបើពួកគេបានចូលរៀនថ្នាក់មត្តេយ្យសិក្សាឱ្យបានត្រឹមត្រូវ។យ៉ាងណាក៏ដោយមិនមែនគ្រប់កុមារទាំងអស់នោះទេបណ្តាកុមារក្នុងគ្រួសារដែលមានប្រាក់ចំណូលទាបចូលរៀនសាលាយ៉ាងយឺតយ៉ាវបើប្រៀបធៀបជាមួយកុមារឯទៀត។ ការសិក្សានូវមត្តេយ្យបានបំពាក់ឱ្យកុមារយ៉ាងច្បាស់នូវជំនាញបុរេទាំងឡាយសំរាប់ការសិក្សាក្នុងសាលាបឋម។ គឺបណ្តាជំនាញបុរេទាំងអស់នោះហើយដែលជាហេតុឱ្យសិស្សទាំងនោះទទួលបាននូវភាពចាស់ទុំជាជាងមិត្តរួមថ្នាក់របស់គេដែលមិនបានចូលមត្តេយ្យទៅលើមុខវិជ្ជាផ្សេងៗនិងមានការយល់ដឹងខ្ពស់ជាង

ក្មេងដែលពុំបានចូលមត្តេយ្យនៅពេលដែលពួកគេឆ្លងចូលបឋមសិក្សាថ្នាក់ទី១។ កុមារមានការសម្របសម្រួលយ៉ាងល្អជាមួយបរិយាកាសថ្នាក់រៀនក៏ដូចជាបរិស្ថានសាលារៀន និងមជ្ឈដ្ឋានជុំវិញខាងក្រៅផ្សេងទៀតដែលបទពិសោធន៍ទាំងនេះពួកគេធ្លាប់បានពើប្រទះកាលពីពួកគេសិក្សានៅថ្នាក់មត្តេយ្យ ។

ការដែលបានឆ្លងកាត់មត្តេយ្យវាជួយកាត់បន្ថយច្រើននៅក្នុងបន្ទុកគ្រួសារព្រោះកុមារចេះម្ចាស់ការទទួលខុសត្រូវនិងទំនុកចិត្តលើខ្លួនឯងព្រមទាំងមានភាពក្លាហានកុមារអាចធ្វើសកម្មភាពប្រចាំថ្ងៃដោយកាត់បន្ថយទៅលើការពឹងផ្អែកទៅលើឪពុក-ម្តាយ និងមនុស្សធំជួយវា ដែលកុមារពុំបានឆ្លងកាត់មត្តេយ្យមានលក្ខណៈពិបាកនិងធ្វើបាន ។កុមារទទួលស្គាល់និងចេះស្រឡាញ់និងជួយថែរក្សាបរិស្ថានជុំវិញខ្លួន និងអាចចែករំលែកបទពិសោធន៍ល្អៗចំពោះមិត្តភក្ត្រ័ ក៏ដូច ជាក្រុមគ្រួសារ ។

**៥.២ ការផ្តល់អនុសាសន៍**

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវខាងលើយើងអាចផ្តល់ជាអនុសាសន៍ខ្លះៗបានថារដ្ឋាភិបាលគួរយកចិត្តទុកដាក់ ទៅលើការអប់រំពីដំបូង នៃវ័យកុមារដែលត្រូវទទួលការអប់រំនៅមត្តេយ្យសិក្សាដោយបង្កើតតំរូវការសម្រាប់ធ្វើឱ្យប្រសើរទៅលើគោលនយោបាយមត្តេយ្យសិក្សាដែលរដ្ឋាភិបាលត្រូវតែដោះស្រាយជាមួយនិងបញ្ហាផ្សេងៗដូចជាកម្មវិធីសិក្សារបស់ថ្នាក់មត្តេយ្យថវិកា/មូលនិធិ និងធនធាននានាសំរាប់ការអប់រំមត្តេយ្យនៅក្នុងប្រទេស។ បង្កើតការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃមត្តេយ្យសិក្សាឱ្យបានជ្រួតជ្រាប់ដល់ឪពុក-ម្តាយឬអាណាព្យាបាលរបស់កុមារទាំងអស់ដែលមានគំនិត អវិជ្ជមានលើការអប់រំនៅមត្តេយ្យសិក្សា។ លើសពីនេះទៅទៀត រដ្ឋាភិបាលគួរបង្កើតនូវគោលនយោបាយក្នុងការលើទឹកចិត្តដល់គ្រូមត្តេយ្យទាំងឡាយដើម្បីឱ្យពួកគាត់ មានអារម្មណ៍ជ្រះស្រឡះល្អក្នុងការផ្តល់ និងផ្ទេរចំណេះដឹងដល់កុមារទាំង។ បង្កើនទំនាក់ទំនងល្អជាដៃគូរអង្គការ ដើម្បីជួយដល់តំបន់ដាច់ស្រយាលលើការពង្រាយមត្តេយ្យសហគមន៍ អប់រំតាមខ្នងផ្ទះ និងការដោះស្រាយបែងចែកកញ្ចប់ថវិការ ក្នុងការលើទឹកចិត្តដល់គ្រូស្ម័គ្រចិត្តដើម្បីជុំរុញមានខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យកុមារបានទទួលនូវសេវា មត្តេយ្យសិក្សាកាន់តែឆាប់រហ័សតាមតែអាចធ្វើទៅបាន ស្របទៅនិងគោលដៅអប់រំសម្រាប់ទាំងអស់គ្នាគឺនៅ ក្នុងឆ្នាំ២០១៥ កុមារទទួលការអប់រំឱ្យបានយ៉ាងហោចណាស់ ៧៥ភាគរយ ។

## ឯកសារយោងៈ


១. The effect of pre-school on academic performance in primary school: as case study of grade one pupils in bostswanna(2002)

២. គោលនយោបាយស្តីពីអប់រំកុមារតូចបោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០០

៣. កុមារ និងការអភិវឌ្ឍ (Save the Children France) by: Chantal Rodier 2001

៤. គោលនយោបាយសង្ខេបស្តីពីកុមារតូចដោយអង្គការ UNESCO 2008

៥. ឯកសារសិក្ខាសាលាស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូចអាយុពី០ ដល់ ៦ឆ្នាំ ឧបត្ថម្ភដោយ Unicef 2005

៦. កម្មវិធីសិក្សាកុមារអាយុ ៥ឆ្នាំ របស់នាយកដ្ឋានអប់រំកុមារតូច ២០០៧

៧. សារណាវិជ្ជាជីវៈរបស់អ្នកស្រី សុខ សោភា ស្តីពីការរៀបចំសកម្មភាពបង្រៀន-រៀនភាសាសរសេរនៅ មត្តេយ្យថ្នាក់កម្រិតខ្ពស់ ឆ្នាំ២០០៤

៨. ចិត្តចលភាពផ្នែកមត្តេយ្យសិក្សា បោះពុម្ពដោយ Enfant du Cambodge ឆ្នាំ២០០០៦

៩. សន្និបាតជាតិអប់រំឆ្នាំ ២០០៦-២០០៧

១០. ទម្រង់តេស្តវាស់សមត្ថភាពកុមារ អាយុពី៥ទៅ៦ឆ្នាំ របស់នាយកដ្ឋានអប់រំកុមារតូច ២០០៧

១១. Harvad Family Research Project (No. I In a sereies spring 2006)

១២. An Evaluation of Early Childhood Care and Education Programmes In Cambodia.( Nirmala Rao and Emma Pearson with assistance from Veronica Pearson and Mark Constas , Final Report: September 1, 2007)

# ឧបសម្ព័ន្ធ

# សំនួរគោលសំរាប់គ្រូបង្រៀនសាលាបឋមសិក្សា
# ការសិក្សាស្រាវជ្រាវមត្តេយ្យសាលា

ខេត្តៈ....................... កាលបរិច្ឆេទនៃបទសម្ភាសន៍:................................

**ព័ត៌មានអំពីប្រវត្តិ ៈ**

ឈ្មោះសាលារៀនៈ…………………… ស្ថិតនៅជាមួយសាលាមត្តេយ្យ ឬអត់ ប្រសិនបើមិននៅជាមួយទេ

តើមានចំណាយប៉ុន្មានពីសាលាមត្តេយ្យដែលនៅក្បែរនោះ......................................................

ឈ្មោះគ្រូបង្រៀន ៈ……………….........

តើមានសិស្សប៉ុន្មាននាក់ដែលកំពុងរៀននៅថ្នាក់ទី ១ ក្នុងឆ្នាំ ២០០៧/២០០៨ ?

តើមានបន្ទប់រៀនចំនួនប៉ុន្មាន (ថ្នាក់ទី ១) តើមានសិស្សប៉ុន្មាននាក់ក្នុង ១បន្ទប់ ?

តើមានថ្នាក់រៀនប៉ុន្មាននៅក្នុងសាលារៀនរបស់អ្នក ? (សូមមើលឯកសារ)

……………………………………………………………………………………………
……………………………………………………………………………………………
…………
……………………………………………………………………………………………
……

## កុមារមកពីសាលាមត្តេយ្យៈ

១-

តើមានកុមារប៉ុន្មាននាក់មកពីសាលាមត្តេយ្យដែលបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១នៅសាលារៀននេះក្នុងឆ្នាំ ២០០៧/ ២០០៨ ?

........................................................................................................................ ............

២-តើមានកុមារប៉ុន្មាននាក់មកពីសាលាមត្តេយ្យនៅក្នុងបន្ទប់នីមួយៗ (ថ្នាក់ទី ១ ឆ្នាំ ២០០៧/ ២០០៨ ) ? តើមានកុមារាប៉ុន្មាននាក់? និង តើមានកុមារីប៉ុន្មាននាក់ ?

| សរុប | កុមារី | កុមារា |
|---|---|---|
| | | |

៣-តើមានអត្រាត្រួតថ្នាក់ប៉ុន្មានក្នុងចំណោមសិស្សមកពីសាលាមត្តេយ្យក្នុងឆ្នាំ ២០០៦ /២០០៧ ?

(សូមមើលឯកសារ)

………………………………………………………………………………………
……
………………………………………………………………………………………
……

៤-តើមានអត្រាបោះបង់ការសិក្សាចំនួនប៉ុន្មាននៅក្នុងថ្នាក់រៀនរបស់អ្នកក្នុងឆ្នាំ ២០០៦/ ២០០៧ ? តើមាន អត្រាបោះបង់ការសិក្សាចំនួនប៉ុន្មានក្នុងចំណោមសិស្សមកពីសាលាមត្តេយ្យ ?

(សូមមើលឯកសារ)

…………………………………

………………………………………………………………………………………
……
………………………………………………………………………………………
……

៥-ប្រសិនបើធ្វើការប្រៀបធៀបរវាងសិស្សបានរៀននៅសាលាមត្តេយ្យ និង សិស្សដែលមិនបានរៀន តើសិស្ស មួយណាប្រសើរជាង ? ឬក៏ដូចគ្នា ? (កំរិតសិក្សា អត្រាបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ និង អត្រា ឡើងថ្នាក់ )

(សូមមើលឯកសារ របស់សាលាតាំងពីមុន និងក្រោយមានសាលាមត្តេយ្យ តាមឆ្នាំសិក្សានីមួយៗ

| ឆ្នាំសិក្សា | **ចំនួនត្រួតថ្នាក់** | | | |
|---|---|---|---|---|
| | **អ្នករៀនមត្តេយ្យ** | | **មិនរៀនមត្តេយ្យ** | |
| | **ភេទ** | | **ភេទ** | |
| | **ប្រុស** | **ស្រី** | **ប្រុស** | **ស្រី** |
| ១៩៩៧-១៩៩៨ | | | | |
| ១៩៩៨-១៩៩៩ | | | | |
| ១៩៩៩-២០០០ | | | | |
| ២០០០-២០០១ | | | | |

| | | | | |
|---|---|---|---|---|
| ២០០១-២០០២ | | | | |
| ២០០២-២០០៣ | | | | |
| ២០០៣-២០០៤ | | | | |
| ២០០៤-២០០៥ | | | | |
| ២០០៥-២០០៦ | | | | |

៧-តើអ្វីទៅជាលក្ខណៈល្អរបស់សិស្សមកពីសាលាមត្តេយ្យ ?

..................................................................

…………………………………………………………………………………………

…………………………………………………………………………………………

………..

៨-តើអ្វីទៅជាលក្ខណៈមិនល្អរបស់សិស្សមកពីសាលាមត្តេយ្យ ?

.............................................................

…………………………………………………………………………………………

…………………………………………………………………………………………

…………

៩-

តាមរយៈបទពិសោធន៍របស់អ្នកតើមានកត្តាអ្វីខ្លះដែលអ្នកគិតថាអាចជួយដល់ការសិក្សារបស់កុមារឱ្យកាន់ តែប្រសើរឡើង ?

.....................................................................................................................

.......................................................................................................................................

.......

.......................................................................................................................................

..................

៩-តើអ្នកមានមតិយោបល់អ្វីខ្លះ ទៅឱ្យរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង ម្ចាស់ជំនួយដើម្បីកែ លំអអត្រាចុះឈ្មោះចូលរៀន និង ការសិក្សារបស់សិស្ស ?

...............................................................

# កម្រងសំនួរសម្រាប់ស្ទាបស្ទង់សមត្ថភាពមូលដ្ឋានកុមារ

## ក.ស្ថានភាពទូទៅ

ឈ្មោះកុមារ.................................................................ភេទ..............អាយុ........................
...

ថ្ងៃខែឆ្នាំកំណើត.....................................................................................................
...

ទីកន្លែងធ្វើតេស្ត.........................................................ថ្ងៃខែឆ្នាំ............................................
...

បានចូលមត្តេយ្យ ☐ មិនបានចូលមត្តេយ្យ ☐ មត្តេយ្យសហគមន៍ ☐ មត្តេយ្យតាមខ្នងផ្ទះ ☐ មត្តេយ្យរដ្ឋ ☐

## ខ.ការអភិវឌ្ឍន៍

### ១.អភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌

| អំណះអំណាង | លទ្ធផលទទួលបាន | | |
|---|---|---|---|
| | បានល្អ | បានខ្លះ | មិនបាន |
| ១.ពេលយើងទៅដល់កុមារចេះជំរាបសួរ ឬទេ? | | | |
| ២.ចូលកូនសំពះចាស់ៗនៅពេលភ្ញៀវមកដល់? | | | |
| ៣.ពេលកូនទៅវត្ត តើកូនថ្វាយបង្គំលោកសង្ឃដូចម្តេច? | | | |
| ៤.ចូរកូនរៀបរាប់ពីបុណ្យសំខាន់ៗនៅក្នុងប្រទេសយើង? (ភ្ជុំបិណ្ឌ អុំទូក ឯករាជ្យ) | | | |
| ៥.ចូរកូនឱ្យឧទាហរណ៍ខ្លឹមសារនៃបុណ្យមួយដែលកូនបានចាំ? | | | |

### ២.អភិវឌ្ឍផ្នែកសុខភាព និងរាងកាយ

| អំណះអំណាង | លទ្ធផលទទួលបាន | | |
|---|---|---|---|
| | បានល្អ | បានខ្លះ | មិនបាន |
| ១.ចូរកូនប្រាប់ពីរបៀបដុសធ្មេញឱ្យអ្នកគ្រូមើល? សិតសក់?នៅពេលណាខ្លះ? | | | |

| | | | |
|---|---|---|---|
| ២.ពេលចេញពីបង្គន់និងមុនញុំាបាយកូនធ្វើដូចម្តេច? ( បានលាងដៃ មិនបានលាង) | | | |
| ៣.ចូរកូនដើរលើបន្ទះក្តារថយក្រោយ | | | |
| ៤.ចូរកូនរើសគ្រាប់ធញ្ញជាតិ( ពោត សណ្តែក ស្រូវ) ដាក់ក្នុងចាន | | | |
| ៥.ចូរកូនឡើងលោតអន្ទាក់ម្នាក់ឯងឱ្យអ្នកគ្រូមើល? | | | |
| ៦.ចូរកូនដោតបំពង់បឺតឆ្លាស់ពណ៌ឱ្យអ្នកគ្រូមើល? | | | |

**៣.អភិវឌ្ឍនផ្នែកភាសា**

| អំណះអំណាង | លទ្ធផលទទួលបាន | | |
|---|---|---|---|
| | បានល្អ | បានខ្លះ | មិនបាន |
| ១.ចូរកូនផ្ទៀងស្តាប់មើល តើជាសំឡេងអ្វី? | | | |
| ២.ចូរកូនរៀបរាប់ពីមុខងាររបស់ច្រមុះ អណ្តាត ត្រចៀក ភ្នែក ស្បែក ? | | | |
| ៣.ពេលកូនទៅផ្សារកូនបានឃើញអ្វីខ្លះ? | | | |
| ៤.តើកូនមានដែលឃើញម្តាយកូនស្លរឺទេ?តើគាត់ធ្វើដូម្តេចដើម្បីស្ល? | | | |
| ៥.ចូរកូនសួរទៅមិត្តថាតើគេចូលចិត្តញុំាអ្វី?រួចប្រាប់អ្នកគ្រូផង | | | |
| ៦.ចូរកូនប្រាប់ឈ្មោះខែទាំង១២ក្នុង១ឆ្នាំ? | | | |
| ៧.ចូរកូនរករូបឆ្មាដែលលាក់ខ្លួនឱ្យបានចំនួនប្រាំពីរ?(១) | | | |
| ៨.ចូរកូនចំលងរូបរាង ក)  ខ)  គ)  ឃ)  ង)  | | | |

**៤.អភិវឌ្ឍនផ្នែកបញ្ញា និងការគិត**

| អំណះអំណាង | លទ្ធផលទទួលបាន | | |
|---|---|---|---|
| | បានល្អ | បានខ្លះ | មិនបាន |
| ១.ចូរកូនប្រាប់ឈ្មោះរាងទាំងនេះ? )រង្វង់ +ត្រីកោណ ១ការេ ចតុកោណ | | | |
| ២.ស្លាបព្រា( ស្លឹកឈើ ផ្លែស្វាយ.......) មានរូបរាងដូម្តេច? | | | |
| ៣.ចូរកូនប្រៀបធៀបរង្វាស់ ប្រវែង វែង ខ្លី វែងជាង វែងបំផុត | | | |

| | | | |
|---|---|---|---|
| ខ្លីបំផុត<br>-ប្រៀបធៀបប្រវែងត្រកួន ២ទង ១ណាវែង ១ណាខ្លី<br>-ជ្រើសរើសត្រកួនតូចជាងគេបំផុតក្នុងចំណោមត្រកួនបីទង និងធំ ជាងគេបំផុត | | | |
| ៤.ចូរធ្វើការប្រៀបធៀបចំនួនតិចជាង ច្រើនជាង( រង្វាស់ទឹកក្នុងកែវ និងចានទាប ) ? | | | |
| ៥.ចូរកូនរៀបចំវត្ថុតាមលំដាប់ពីតូចទៅធំ?( ស្លឹកឈើ ផ្កា......) | | | |

(១) ផ្ទាំងគំនូរដែលនៅក្នុងនោះមានរូបឆ្មាប្រាំពីរលាក់ខ្លួននៅជាមួយរបស់ផ្សេងៗ ។

## ៥.អភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍

| អំណះអំណាង | លទ្ធផលទទួលបាន | | |
|---|---|---|---|
| | បានល្អ | បានខ្លះ | ិនបាន |
| ១.ចូរកូនផ្គុំរូបមនុស្ស? | | | |
| ២.ចូរកូនដើរតួធ្វើជាឪពុកម្ដាយ ដោយប្រើរូបតុក្កតា? | | | |
| ៣.ចូរកូនគូររូបមួយដែលកូនពេញចិត្ត? | | | |
| ៤.តើកូនចូលចិត្តអ្នកណាជាងគេនៅក្នុងគ្រួសារកូន? | | | |
| ៥.តើកូនចូលចិត្តលេងល្បែងអ្វីជាងគេ?( បាល់ទាត់ លេងមីក លោតអន្ទាក់...) | | | |

៚៚៚